សមាគមបុគ្គលិកសិក្សាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

កម្មវិធីស្ដារឡើងវិញដោយមានជំនួយពីសហគមន៍អឺរ៉ុប
កម្មវិធីជំនួយលើសិក្សាធិការផ្នែកបឋមសិក្សានៅកម្ពុជា

# ទស្សនាវដ្ដី លេខ ២

# គ្រូបង្រៀន



ខែ មករា - កុម្ភៈ - មីនា ១៩៩៦
ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨ B. មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរសព្ទ 015 918 124

# មាតិកាអត្ថបទ


**១ - សមាគមបុគ្គលិកសិក្សាខ្មែរ**

- សមាសភាពគណៈកម្មាធិការនាយកនៃ ស.ប.ស.ខ និងគណៈត្រួតពិនិត្យហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៦
- ការអនុវត្តន៍សេចក្តីសំរេចរបស់មហាសន្និបាតឆ្នាំ ១៩៩៥
- ការណែនាំអនុវត្តពីការបង់វិភាគទានប្រចាំខែ និងវិភាគទានឧបត្ថម្ភសពរបស់មន្ត្រីអប់រំចូលនិវត្តន៍
- គោលដៅ ស. ប. ស. ខ ( កំណាព្យ )

**២ - ពតិមានរដ្ឋបាល**

- សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា (ត) ជំពូកទី ៤

**៣ - ទស្សនមិត្តទៅ - ការអប់រំ**

- ភ្នំព្រះរាជទ្រព្យ និង វិហារអដ្ឋរស
- ស្តាយកេរចាស់ ( កំណាព្យ )
- បរិដ្ឋានបរិយាកាស - ទឹកជំនន់

**៤ - ការអប់រំ & គរុកោសល្យ**

- អភិវឌ្ឍន៍ធនធានមនុស្ស
- គោលបំណងនៃការបង្រៀនប្រវត្តិវិទ្យា និងភូមិវិទ្យា នៃប្រទេសកម្ពុជា
- ស្វែងយល់ពីមេរៀនប្រវត្តិវិទ្យា
- គុណសម្បត្តិអ្នកអប់រំ
- បង្រៀន គឺជ្រើសរើស

**៥ - ការប្រលងជ្រើសរើសអធិការបឋមសិក្សា**

ជំនាន់ទី២ ( សម័យប្រលងថ្ងៃទី ១០ - ១០ - ៩៥ )

**៦ - ទេពិកាស្មេរិន**

- សេចក្តីអំពាវនាវ




## I- គណៈកម្មការតំរង់ទិស - អំណាន និងតាមដាន

1 - លោក យឹង ធី ប្រធាន
2 - លោក ស៊ិន ងួនហេង សមាជិក
3 - លោក ណាត ប៊ុនរឿន សមាជិក
4 - លោក ធ សោ សមាជិក
5 - លោក ជា ជាតិ សមាជិក
6 - លោក ស៊ុង វ៉ាន់ថន សមាជិក
7 - លោកស្រី ហ៊ួរ សិរី សមាជិក
8 - លោក សង់ មីសែលឡឺប៊ុច សមាជិក
9 - លោក សោភា រិទ្ធ សមាជិក

## II - គណៈកម្មការតែងអត្ថបទ

1 - លោក យឹង យ៉ាណូ
2 - លោក ឆយ យីហាំង
3 - លោក អ៊ុម កុច
4 - លោក កង ឱម
5 - លោក ពត សុត
6 - លោក ផិន សុកហេង
7 - អ្នកស្រី ផាន់ សំអោ
8 - អ្នកស្រី អ៊ិច សារ៉ូ
9 - លោក សំអាន សាយ
10 - លោក ប្រាក់ ព្រុំ
11 - លោកអធិការបឋមសិក្សានៅគ្រប់ខេត្ត - ក្រុង
បណ្តុះបណ្តាលនៅមហាវិទ្យាល័យគរុកោសល្យ


ទស្សនាវដ្តីនេះបោះពុម្ពដោយមានការរួមចំណែកជាបច្ចេកទេស និងហិរញ្ញវត្ថុ

**ពី កម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សានៅកម្ពុជារបស់សហគមន៍អឺរ៉ុប**

Revue publiée avec le concours technique et financier du Programme d'Appui au Secteur de l'Education Primaire au Cambodge ( PASEC ) de l'Union Européenne.



# ព័ត៌មានសមបុគ្គលិកសិក្សាខ្មែរ



## I- សមាសភាពគណៈកម្មាធិការកណ្ដាលនៃ ស.ប.ស.ខ និងគណៈត្រួតពិនិត្យ ហិរញ្ញវត្ថុ... 

| | | |
|---|---|---|
| ១- | លោក យ៉ង់ ធី | ប្រធាន |
| ២- | លោក ជុំ ហ៊ុន | អនុប្រធាន |
| ៣- | លោក កុយ វុន | អគ្គលេខាធិការ |
| ៤- | លោក ស្វាយ ទិត្យ | អនុលេខាធិការ |
| ៥- | លោក កែវ យ៉ារ | អគ្គហិរញ្ញិក |
| ៦- | លោក កៅ ជឿន | អនុហិរញ្ញិក |
| ៧- | លោក ថោង ប៊ុរិន្ទ | បណ្ណារក្ស |
| ៨- | លោកស្រី ហួរ ស៊ីរី | បណ្ណារក្ស |
| ៩- | លោក ស៊ុន ស៊ុម | ស្នងការ |
| ១០- | លោក ស៊ុន ជួរ | ស្នងការ |
| ១១- | អ្នកស្រី ប្រាក់សូលីដា | ស្នងការ |
| ១២- | លោក គី ទូច | ស្នងការ |
| ១៣- | លោក សួង សារុន | ប្រធានគណៈត្រួតពិនិត្យ |
| ១៤- | លោក បែន សារិន | សមាជិកគណៈត្រួតពិនិត្យ |
| ១៥- | លោកស្រី ទន់ សុគ្គំ | សមាជិកគណៈត្រួតពិនិត្យ |

## II- ការអនុវត្តន៍សេចក្ដីសំរេចរបស់មហាសន្និបាតឆ្នាំ ១៩៩៥

### ក- បញ្ហាប្រាក់ឧបត្ថម្ភសពា

បទបញ្ញាស្ដីពីការផ្ដល់ជំនួយ និងបង់វិភាគទានក្នុងប្រការ ១ ; ២ ; ៣ និង ៥ ( លក្ខន្តិកៈសមាគមទំព័រ ២២ , ២៣ , ២៤ , ២៥ ) ត្រូវបានទុកជានិរាករណ៍ ហើយត្រូវបានជំនួសដោយប្រការថ្មីដូចខាងក្រោម ។ ប្រការ៤

និងប្រការផ្សេងទៀតនៃបទបញ្ជា ត្រូវបានរក្សាទុកអនុវត្តដដែល ។

**ប្រការ ១ ថ្មី:** ជំនួយត្រូវបានកំណត់ជាស្ថាពរដូចតទៅ ៖

ក- ១.៣០០.០០០៛ ចំពោះសមាជិកម្នាក់ស្លាប់ ។

ខ- ១.៣០០.០០០៛ ចំពោះសមាជិកដែលព្រះរាជរដ្ឋាភិបាលបញ្ឈប់ដោយសុខភាព មិនអនុញ្ញាតអោយធ្វើការតទៅទៀតបាន ។

បុព្វហេតុសុខភាពក្នុងករណីនេះ គឺ ៖ របេង ឆ្កួត ខ្វាក់ ខ្វិន ជាដើម ។

គ- ៦៥០.០០០៛ ចំពោះភរិយាទី១ ឬស្វាមីពេញច្បាប់របស់សមាជិក ស្លាប់ ។

ឃ- បើស្វាមី ភរិយា ជាសមាជិកទាំងពីរនាក់ ហើយទទួលមរណភាពក្នុងពេលជាមួយគ្នា សាមីជនត្រូវទទួលអំណោយរៀងៗខ្លួន ក្នុងឋានៈជាសមាជិក គឺម្នាក់ៗ ១.៣០០.០០០៛ ។

ង- បើស្វាមី ភរិយា ជាសមាជិកទាំងពីរនាក់ ហើយអ្នកណាម្នាក់ទទួលមរណៈភាពនោះ ត្រូវទទួលជំនួយ ១.៩៥០.០០០៛ គឺ ៖

១.៣០០.០០០៛ ក្នុងឋានៈជាសមាជិក

៦៥០.០០០៛ ក្នុងឋានៈប្តី ឬ ប្រពន្ធជាសមាជិក

**ប្រការ ២ :** ដើម្បីអនុវត្តនូវប្រការ ១ ខាងលើ សមាជិកសមាគមម្នាក់ៗ ត្រូវបង់វិភាគទានពិសេស ដូចតទៅ ៖

២០៛ បើមានសមាជិកម្នាក់ស្លាប់

២០៛ បើមានសមាជិកណាម្នាក់ ត្រូវព្រះរាជរដ្ឋាភិបាលបញ្ឈប់ដោយសុខភាព ។

១០៛ បើមានភរិយាទី១ ឬស្វាមីពេញច្បាប់ណាម្នាក់ស្លាប់ ។

**ប្រការ ៣ :** វិភាគទានខាងលើ អាចនឹងប្រែប្រួលបានដោយសេចក្តីសំរេចរបស់មហាសន្និបាត ដែលមានសមាជិកយល់ព្រមចាប់ពី ២/៣ ឡើងទៅ ។

**ប្រការ ៤ :** ( រក្សាទុកដដែល )

**ប្រការ ៥ :** ចាប់ពីសពទី១ នៃសមាជិក ឬ គូស្រករសមាជិកដែលទទួលមរណៈភាព គិតពីម៉ោងសូន្យនៃថ្ងៃទី ០១ ខែតុលា ឆ្នាំ១៩៩៥ តទៅសមាជិកម្នាក់ៗត្រូវបង់ ២០៛ ឬ ១០៛ ទៅតាមករណីដូចមានចែងក្នុងប្រការ ២ ។

### ខ - ការកំនត់ពេលវេលាសុំចូលជាសមាជិក ស.ប.ស.ខ

#### *ក) ចំពោះគ្រូថ្មី*

បុគ្គលិកសិក្សាចេញថ្មីត្រូវបានអនុញ្ញាតអោយចូលជាសមាជិក ស.ប.ស.ខ. ចាប់ពីកាលបរិច្ឆេទនៃប្រកាសតែងតាំងជាមន្ត្រីអប់រំបំរុងរាជការ ។ ផុតរយៈពេលមួយឆ្នាំ ប្រសិនបើលោកគ្រូ អ្នកគ្រូថ្មីនេះ មិនបាន

សុំចូលជាសមាជិកទេនោះ គណៈកម្មាធិការខេត្ត - ក្រុងនឹងមិនអនុញ្ញាតអោយចូលឡើយដោយយល់ថា គ្រូថ្មីនេះមិនមានស្មារតីចង់ឧបត្ថម្ភគ្នាទៅវិញទៅមកក្នុងអង្គបុគ្គលិកសិក្សារបស់ប្អូន ។

*ខ) ចំពោះគ្រូចាស់*

បុគ្គលិកសិក្សាចាស់ ដែលមកទល់ថ្ងៃនេះ មិនទាន់បានសុំចូលជាសមាជិក ស.ប.ស.ខ. នៅឡើយ នឹងត្រូវផុតកំនត់អោយចូលយ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ធ្នូ ១៩៩៨ ជាកំហិត ។

## III - ការណែនាំអនុវត្តពីការបង់វិភាគទានប្រចាំខែ និងវិភាគទានឧបត្ថម្ភសពរបស់មន្ត្រីអប់រំចូលនិវត្តន៍

ដើម្បីបង្ហាញនូវទឹកចិត្តដ៏ស្មោះស្ម័គ្រចំពោះសមាគមនិវត្តជនទាំងឡាយគួរតែអនុវត្តតាមវិធីពីរខាងក្រោម ៖

១- ដំកល់ប្រាក់មួយចំនួនទៅអង្គភាពដើមរបស់ខ្លួន ។ ប្រាក់នេះត្រូវផ្ញើទុកនឹងបុគ្គលិកទទួលបន្ទុកការងារ ស.ប.ស.ខ. ដោយមានបង្កាន់ដៃទទួលត្រឹមត្រូវ ។ ការបង់វិភាគទានប្រចាំខែ និងវិភាគទានឧបត្ថម្ភសពត្រូវបញ្ជាក់ដោយប័ណ្ណនៅពេលអស់ប្រាក់ផ្ញើនោះ ។

២- ពឹងពាក់មិត្តភក្តិដែលទុកចិត្តកំពុងបំរើការងារនៅឡើយអោយជួយបង់ជួសនៅពេលបើកបៀវត្សរាល់ខែ ។ តាមវិធីនេះអ្នកទទួលបញ្ញើត្រូវបង់ពីរចំនែក គឺចំនែកមិត្តភក្តិ និងចំនែកខ្លួនឯងផ្ទាល់ ។

## IV - ការកែលំអទំរង់បែបបទសុំចូលជាសមាជិកសមាគម

ដើម្បីធានាបានការស្មោះត្រង់ និងទប់ស្កាត់ការក្លែងបន្លំនៃសមាជិកខ្វះមនសិការ និងខ្វះភាពចរិតទៀតត្រង់ សមាជិកទាំងអស់ត្រូវអនុវត្តទំរង់បែបបទថ្មីដូចខាងក្រោម ។

១- ចំពោះសមាជិកចាស់ដែលដាក់ពាក្យសុំចូលរួចហើយ ត្រូវធ្វើសលាកប័ត្រពត៌មានបន្ថែមលើប្តី រឺ ប្រពន្ធ ហើយត្រូវបិទរូបថតផង ។ សលាកប័ត្រនេះត្រូវធ្វើជាពីរច្បាប់ ។

២- ចំពោះបុគ្គលិកសិក្សាថ្មី និងចាស់ដែលពុំទាន់បានសុំចូលជាសមាជិកសមាគមនៅឡើយ ត្រូវធ្វើពាក្យសុំចូលជាសមាជិក និងពាក្យបណ្តាំ ហើយបិទរូបថតទាំងប្តី ទាំងប្រពន្ធ រឺទាំងប្រពន្ធទាំងប្តី ។ ពាក្យសុំនេះត្រូវធ្វើជាពីរច្បាប់ ។ សលាកប័ត្ររបស់សមាជិកចាស់ និងពាក្យសុំចូលជាសមាជិកថ្មី ត្រូវដំកល់ទុកនៅសមាគម ស.ប.ស.ខ. ខេត្ត - ក្រុងមួយច្បាប់ និងផ្ញើមកគណៈកម្មាធិការកណ្តាលមួយច្បាប់ ។

* គំរូសលាកប័ត្រពត៌មាន ពាក្យសុំចូលជាសមាជិក និងពាក្យបណ្តាំមានដំកល់ទុកនៅគ្រប់គណៈកម្មាធិការខេត្ត - ក្រុងនៃ ស. ប. ស.ខ

# គោលដៅ ស.ប.ស.ខ

**បទពាក្យ ៨**

- សមាគមបុគ្គលិកសិក្សាខ្មែរ ពាក្យកាត់ហៅតែ ស.ប.ស.ខ
  បានរស់ឡើងវិញ ស្រស់បវរ សមាជិកកុះករ ជួយគាំទ្រ ។
- មជ្ឈដ្ឋានគ្រូគ្រប់ កំរិតសិក្សា តែងមានចិត្តប្រាថ្នា អរសាទរ
  យល់ច្បាស់គោលដៅ ចិត្តនឹងនរ ទាំងអស់គ្នាជូនពរ បានជោគជ័យ ។
- គោលដៅទីមួយ រឹតសាមគ្គីភាព រឹតចំនងមិត្តភាព មិនព្រួយភ័យ
  យោគយល់ទុកចិត្តគ្នាមិនកេងកៃ ផ្ដល់គំនិតវាងវៃ ស្ដាប់គ្នា ។
- គោលដៅទីពីរ ដឹងសុខដឹងទុក្ខ ទោះមិនបានជួបមុខ អាចពណ៌នា
  តាមលិខិតជូនដំណឹងដល់គ្នា តាមបណ្ដាញផ្សាយជាប្រចាំផង ។
- គោលដៅទីបីជួយសមត្ថភាព ទោះយល់ដឹងខ្ពស់ទាប មានបំនង
  បង្កើនគរុកោសល្យគ្រាគន្លង បណ្ដុះបណ្ដាលវគ្គឆ្លង រយៈពេលខ្លី ។
- ជួយគ្រូដែលមានវប្បធម៌នៅទាប ខំបំប៉ន បញ្ជ្រាប ផ្ដែកទ្រឹស្ដី
  ផ្សព្វផ្សាយបណ្ដាញទស្សនាវដ្ដី គ្រប់អត្ថបទវែងខ្លី ជាមេរៀន ។
- គោលដៅទីបួន ពង្រឹងគុណធម៌ វិជ្ជាជីវៈល្អ គ្រូបង្រៀន
  មានមនសិការជាតិ ទស្សនាទាន ធ្វើការប្រឹតប្រៀន ខំសិក្ស ។
- ត្រូវលើកស្ទួយកិត្តិយសគ្រូឡើងវិញ រៀបឫកពា បំពេញតួនាទី
  ជាគ្រូល្អ សិស្សគោរពគ្រប់ទិសទី ចេះរួបរួមសាមគ្គីជាគំរូ ។
- គោលដៅទាំងបួនរៀបរាប់ខាងលើ សុទ្ធសឹងជាទង្វើគ្រូវតស៊ូ
  ពង្រឹងគុណភាពក្នុងសមាគមគ្រូ គុណភាពអប់រំយូរលង់អង្វែង ។
- ដូចនេះ លោកគ្រូ អ្នកគ្រូទាំងអស់ ត្រូវមានចិត្តស្មូគ្រស្មោះខំស្វះស្វែង
  អានទស្សនាវដ្ដី អត្ថបទថែង ស្មាដៃប្រឹងប្រែង ស.ប.ស.ខ. ។

**ដោយលោកស្រី ហួរ សិរី**

# ច្បាប់

## ស្តីពី

## សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ៤

## ការឡើងឋានន្តរស័ក្តិ រឺ ឡើងថ្នាក់

**មាត្រា ២០.**

ការឡើងឋានន្តរស័ក្តិ រឺឡើងថ្នាក់នៃអ្នករាជការត្រូវធ្វើតាមវេនជ្រើសរើសក៏បាន រឺតាមវេនជ្រើសរើស និងអតីតភាពជាមួយគ្នាក៏បាន ។

តាមធម្មតា រយៈពេលអប្បបរមានៃការឡើងថ្នាក់ត្រូវកំរិត ២ ឆ្នាំ ។ ដើម្បីនឹងអាចឡើងថ្នាក់តាមការជ្រើសរើសយកនោះ ត្រូវមានចុះឈ្មោះក្នុងតារាងឡើងថ្នាក់ ។ ក្នុងករណីអ្នករាជការណាម្នាក់បំពេញការងារមានស្នាដៃល្អពិសេសត្រូវបានតំលើងថ្នាក់ជាស្វ័យប្រវត្តិ ដោយពុំគិតពីលក្ខខ័ណ្ឌអតីតភាពឡើយ ។

ចំពោះក្របខ័ណ្ឌទាំងអស់ ការតំលើងថ្នាក់ត្រូវមានការយល់ព្រមពីស្ថាប័នមានសមត្ថកិច្ចក្នុងការតែងតាំង ដែលសំរេចអោយតាមកំរិតនៃកន្លែងទំនេរក្នុងឋានន្តរស័ក្តិនីមួយៗ និងតាមកំរិតមុខចំណាយថវិកា ។

**មាត្រា ២១.**

អ្នករាជការក្នុងឋានន្តរស័ក្តិតែមួយអាចឡើងថ្នាក់បានម្តងមួយថ្នាក់ បើដូរឋានន្តរស័ក្តិត្រូវឡើងទៅថ្នាក់ក្រោមបំផុតនៃស័ក្តិខ្ពស់ជាងនោះ ។ នៅពេលដែលអ្នករាជការត្រូវប្តូរប្រភេទក្របខ័ណ្ឌ ដោយសារបានប្រឡងជាប់ទៅប្រភេទក្របខ័ណ្ឌខ្ពស់ សន្ទស្សន៍បៀវត្សត្រូវគិតត្រឹមថ្នាក់ដែលមានកំរិតស្មើ រឺខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់នៃអ្នករាជការនោះ ។

ការតំលើងឋានន្តរស័ក្តិ រឺ ថ្នាក់ទាំងឡាយ ត្រូវគិតលើផ្នែកបៀវត្សនិងអតីតភាពចាប់ពីកាលបរិច្ឆេទដែលការតំលើងឋានន្តរស័ក្តិនេះត្រូវបានប្រកាស ។

**មាត្រា ២២.**

ជារៀងរាល់ឆ្នាំ នៅខែមេសា អ្នករាជការទាំងអស់ដែលមានសិទ្ធិត្រូវតំលើងឋានន្តរស័ក្តិ រឺ ថ្នាក់ ត្រូវបំពេញព្រឹត្តិប័ត្រពិន្ទុសំរាប់តំលើងថ្នាក់របស់ខ្លួន ។ ព្រឹត្តិប័ត្រពិន្ទុនេះត្រូវបានប្រធានអង្គភាពធ្វើការកត់សំគាល់ និង

បញ្ជាក់បន្ថែម ព្រមទាំងកំណត់ជាពិន្ទុ ។

អភិបាលខេត្ត ក្រុង មានភារៈផ្តល់យោបល់ទៅលើកិរិយាមារយាទ ការគោរពវិន័យសាមគ្គីភាពរបស់ប្រធានមន្ទីរនានានៅខេត្ត ក្រុង ។

តារាងពិន្ទុទាំងនោះត្រូវបញ្ជូនតាមលិខិតសំងាត់ទៅប្រធានស្ថាប័នសាមុី ។

## មាត្រា ២៣.

ក្រោយពីបានចារលើព្រឹត្តិប័ត្រពិន្ទុ តាមក្របខ័ណ្ឌ និងលំដាប់លំដោយអតីតភាព ប្រធានអង្គភាព រឺ ប្រធានស្ថាប័នមានសមត្ថកិច្ចបញ្ឈប់បញ្ជីស្នើសុំឡើងថ្នាក់នោះ ។

បញ្ជីខាងលើនេះ ត្រូវចុះឈ្មោះអ្នករាជការដែលបានបំពេញលក្ខខ័ណ្ឌដូចខាងក្រោម ៖

១- តាមធម្មតា អតីតភាពការងារយ៉ាងតិចបាន ២ ឆ្នាំ ចំពោះឋានន្តរស័ក្តិ រឺថ្នាក់ដែលបានទទួលគិតចាប់ពីថ្ងៃចូលឆ្នាំខ្មែរ ដែលជាថ្ងៃធ្វើតារាងឡើងថ្នាក់ ។

២- ត្រូវមានសេចក្តីស្នើសុំអោយឡើងថ្នាក់ត្រឹមត្រូវតាមច្បាប់ ពីថ្នាក់គ្រប់គ្រងបន្តបន្ទាប់ដែលសាមុីខ្លួននៅក្រោមបង្គាប់ ។

## មាត្រា ២៤.

ព្រឹត្តិប័ត្រកំណត់ពិន្ទុវិជ្ជាជីវៈ និងស្ថានភាពសេវាកម្មនៃរាជការម្នាក់ៗដែលស្នើសុំឡើងឋានន្តរស័ក្តិ រឺថ្នាក់ត្រូវដាក់អោយគណៈកម្មការចំណាត់ថ្នាក់ពិនិត្យ ។

## មាត្រា ២៥.

តារាងតំលើងឋានន្តរស័ក្តិ រឺ ថ្នាក់ ត្រូវធ្វើដោយគណៈកម្មការចំណាត់ថ្នាក់តែងតាំងតាមសំណើប្រធានអង្គភាព រឺ ពីប្រធានស្ថាប័នសាមុី ។

គណៈកម្មការនេះ ត្រូវតែងតាំងឡើងតាមព្រះរាជក្រិត្យ អនុក្រិត្យ រឺ តាមប្រកាសក្រសួង ហើយត្រូវមានសមាសភាពដូចតទៅ ៖

១- ប្រធានស្ថាប័ន រឺ តំណាង ប្រធាន

២- ប្រធានអង្គភាពដែលគ្រប់គ្រង រឺ តំណាង សមាជិក

៣- ប្រធានការិយាល័យបុគ្គលិក រឺ តំណាង សមាជិក

៤- អ្នករាជការពីរនាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នាតែមានឋានន្តរសក្តិ និងថ្នាក់ខ្ពស់ជាង រឺបើគ្មានទេ ត្រូវយកអ្នករាជការក្នុងក្របខ័ណ្ឌឯទៀតក៏បានដែរ ។ អ្នករាជការទាំងនេះត្រូវជ្រើសរើសឡើងដោយការបោះឆ្នោត សមាជិក

## មាត្រា ២៦.

តារាងតំលើងឋានន្តរស័ក្តិ រឺថ្នាក់ ត្រូវធ្វើឡើងក្នុងត្រីមាសទី ៤ នៃឆ្នាំនីមួយៗ ( ត្រីមាសទី ៤ នៃ ឆ្នាំខ្មែរ ) ។ តារាងនេះប្រើការសំរាប់ឆ្នាំបន្ទាប់ និងមានតែឈ្មោះអ្នកដែលស្នើឡើងតាមវេនជ្រើសរើស ។

គណៈកម្មការចំណាត់ថ្នាក់ប្រជុំពេញអង្គ កំណត់មធ្យមភាពនៃពិន្ទុចំពោះបេក្ខជនម្នាក់ៗពីពិន្ទុ ០ ដល់ពិន្ទុ ២០ រួចគណៈកម្មការនេះស្រង់ឈ្មោះបេក្ខជនតាមលំដាប់លំដោយពិន្ទុ ។

ការចុះឈ្មោះក្នុងតារាងតំលើងឋានន្តរស័ក្តិថ្នាក់ ត្រូវធ្វើតាមចំនួនកន្លែងដែលមានសល់ទំនេរ ។

ចំនួនឈ្មោះដែលចុះក្នុងតារាងតំលើងឋានន្តរស័ក្តិ រឺថ្នាក់ប្រចាំឆ្នាំសំរាប់ក្របខ័ណ្ឌនិមួយៗនៅក្នុងឋានន្តរស័ក្តិរឺថ្នាក់និមួយៗ ត្រូវកំណត់ដោយព្រះរាជក្រិត្យ អនុក្រិត្យរឺប្រកាសតាមចំនួនកន្លែងទំនេរ និងតាមមុខចំណាយដែលមានគ្រោងទុកក្នុងថវិកា ។

**មាត្រា ២៧.**

ក្នុងករណីដែលមិនអាចចុះឈ្មោះបេក្ខជនទាំងអស់ក្នុងតារាងតំលើងឋានន្តរស័ក្តិ រឺថ្នាក់នៃឆ្នាំនេះបានទេ សាមីខ្លួនត្រូវមានសិទ្ធិចុះឈ្មោះមុនគេបង្អស់តាមលេខរៀង ក្នុងតារាងតំលើងឋានន្តរស័ក្តិ រឺថ្នាក់ឆ្នាំបន្ទាប់មកទៀត លើកលែងតែគណៈកម្មការសំរេចផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុផលពីប្រធានគ្រប់គ្រងសាមី ។

**មាត្រា ២៨.**

ដើម្បីចុះឈ្មោះក្នុងតារាងឡើងឋានន្តរស័ក្តិ រឺថ្នាក់បាននៅថ្ងៃ ១៣ ខែ មេសា ក្នុងឆ្នាំ និមួយៗ បេក្ខជនត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃអង្គរបស់ខ្លួន ដើម្បីឡើងថ្នាក់ ។ ក្នុងករណីពិសេស គណៈកម្មការចំណាត់ថ្នាក់មានសិទ្ធិចុះឈ្មោះក្នុងតារាងតំលើងឋានន្តរស័ក្តិ រឺថ្នាក់បានទូវអ្នករាជការណាដែលអង្គភាពគ្រប់គ្រងមិនបានស្នើសុំតំលើងឋានន្តរស័ក្តិរឺថ្នាក់ ។

**មាត្រា ២៩.**

អតីតភាពការងារមន្ត្រី រាជការដែលធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាល តំបន់ប៉ះពាល់សុខភាពរឺគ្រោះថ្នាក់ ត្រូវគិតបន្ថែមពាក់កណ្តាលនៃអតីតភាពនេះទៀត ក្នុងការចុះឈ្មោះលើតារាងរាយនាមសំរាប់ស្នើសុំតំលើងឋានន្តរស័ក្តិរឺថ្នាក់ ។

**មាត្រា ៣០.**

ការតំលើងឋានន្តរស័ក្តិរឺថ្នាក់តាមវេនអតីតភាព ត្រូវឆ្លាស់គ្នាជាមួយការឡើងឋានន្តរស័ក្តិ រឺថ្នាក់តាមវេនជ្រើសរើស ទៅតាមសមាមាត្រដែលបានគ្រោងទុកក្នុងលក្ខន្តិកៈដោយឡែកសំរាប់អង្គនីមួយៗ ។

ការឡើងឋានន្តរស័ក្តិ រឺ ថ្នាក់តាមវេនអតីតភាព ត្រូវសំរេចតាមលំដាប់លំដោយអតីតភាពជាដាច់ខាតក្នុងបញ្ជីរាយនាមអ្នករាជការដែលត្រូវសុំអោយឡើងឋានន្តរស័ក្តិថ្នាក់នោះ ។

**មាត្រា ៣១.**

សិទ្ធិត្រូវបានឡើងឋានន្តរស័ក្តិរឺថ្នាក់ ដោយវេនជ្រើសរើស ក៏ដូចជាដោយវេនអតីតភាព ត្រូវផ្អាកចំពោះអ្នករាជការណាដែលជាប់ចោទជាបទវិន័យរឺជាបទតុលាការ ។

**មាត្រា ៣២.**

ឋានន្តរស័ក្តិកិត្តិយស អាចផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចតែងតាំងជូនមន្ត្រីរាជការចូលនិវត្តន៍រឺលាលែងរឺដែលបានដាក់អោយឈប់ធ្វើការងារដោយបាត់បង់សមត្ថភាពការងារ ។

ឋានន្តរស័ក្តិជាកិច្ចបញ្ចុះសពមរណៈអាចផ្តល់ជូនមន្ត្រី រាជការដែលបានទទួលមរណភាព ។



# ភ្នំព្រះរាជទ្រព្យ និង វិហារអដ្ឋារស (១)

**របស់ក្រុមជំនុំទំនៀមទំលាប់**

**ទស្សនាវដ្តី កម្ពុជសុរិយា លេខ ១០ ខែ តុលា ១៩៦៣**

**ទស្សនាវដ្តីគ្រូបង្រៀនលេខ ៨ ខែ ឧសភា គ.ស ១៩៦៤**





ភ្នំព្រះរាជទ្រព្យបង្កប់រឿងអាថិកំបាំងគួរអោយចង់ស្តាប់ ។

ការស្គាល់ភ្នំនេះមុនឆ្នាំ ១៩៧០ និងក្រោយឆ្នាំ ១៩៧៩ ធ្វើអោយទស្សនិកជនសោកសង្រេក អណោចអធម៌ ដោយឃើញស្នាដៃអ្នកបំផ្លាញសាហាវពេក អធមិពេក ។

លោកគ្រូ - អ្នកគ្រូយើងខ្លះ មិនបានស្គាល់ភ្នំនេះនៅឡើយទេ ។ គួរតែឆ្លៀតឱកាសនៅពេលណាមួយ ។ កាលឃើញមុន និងក្រោយការបំផ្លាញ ទើបមានចិត្តរំភើបញាប់ញ័រពីការខូចខាត ។

សូមជំរាបថា វិហារអដ្ឋារស រឺ វិហារព្រះធំ ( ហៅតាមអ្នកស្រុក ) ត្រូវរលំរលាយបាត់ស្រមោល ។ សព្វថ្ងៃទស្សនិកជនបានឃើញតែខឿន និងឥដ្ឋតែប៉ុននោះ ។ រីឯចេតិយរបស់ព្រះរាជវង្សានុវង្ស ត្រូវក្រុមអ្នកបំផ្លាញគាស់ទ្វាររុករានទន្រ្ទានរកវត្ថុមានតំលៃ ។ ព្រះគោក៏ត្រូវបានកាប់អោយមានប្រហោងលូករាវរកសម្បត្តិនៅខាងក្នុង ។

កាលណាយើងធ្វើដំណើរចេញពី **ភ្នំពេញ** តាមផ្លូវជាតិលេខ ៥ ( ផ្លូវពីភ្នំពេញ ទៅបាត់ដំបង ) ចំងាយ ៣៧ គីឡូម៉ែត្រ យើងនឹងប្រទះឃើញផ្លូវចូលមួយខាងឆ្វេងដៃឆ្ពោះទៅទិសខាងលិច ដែលមានចាក់ជ័រកៅស៊ូយ៉ាង

(១) : អដ្ឋរស្សប្រាំបីជ្រុង : វិហារអដ្ឋរស្ស ។ គេធ្លាប់សរសេរថា អដ្ឋារស ‹‹ ១៨ ›› ឥតពាក្យថា ‹‹ ជ្រុង ››

ស្អាតស្អំ ។ បើយើងចូលតាមផ្លូវខេត្តនេះទៀតចំងាយតែ ៣ គីឡូម៉ែត្រប៉ុណ្ណោះ នឹងទៅដល់ជើងភ្នំមួយដ៏មានទេសភាពស្រស់ប្រិមប្រិយ គ្របដណ្តប់ទៅដោយព្រៃព្រឹក្សាលតាវល្លិពណ៌បៃតងស្រងាត់នឹងមានកំពូលចេតិយ កំពូលព្រះវិហារ លេចចេញផុតពីចុងព្រឹក្សាទាំងនោះផង ។ ភ្នំវែងសណ្តូកទទឹងថ្ងៃនេះហើយដែលហៅថា " **ភ្នំព្រះរាជទ្រព្យ** " ។ សព្វថ្ងៃទីតាំងភ្នំនេះទាំងមូលឋិតនៅក្នុងឃុំ **ផ្សារដែក ស្រុកពញាឮ** ខេត្ត **កណ្តាល** ដ៏មានអ្នកស្រុក អ្នកភូមិរស់នៅជាហូរហែតាមដងផ្លូវ ចូលពីផ្លូវជាតិទៅ នឹងតាមផ្លូវលំព័ទ្ធជុំវិញជើងភ្នំនេះផង ។ នៅជាប់នឹងជើងភ្នំខាងកើតលើផ្ទៃដីរាបធំធេងស្រឡះស្រឡំ មានវត្តមួយស្អាតបាតឈ្មោះ " **ចន្ទគុត** " ។ ទន្ទឹមនឹងវត្តនេះ មានផ្លូវជាជណ្តើរឡើងទៅលើ ភ្នំដែលរចនាពីផែនថ្មបាយក្រៀមធ្វើជាកាំយ៉ាងទូលាយ ហើយវែងលលៃ បត់បែនពេនពង់ទៅតាមសណ្ឋានដីចំណោតភ្នំ ។ ហួសពីវត្តនេះទៅជិតមួយគីឡូម៉ែត្រទៀតទើបផុតថ្នល់ចាក់កៅស៊ូ ។ ត្រង់ផុតថ្នល់កៅស៊ូនោះ មានជណ្តើរមួយទៀតធ្វើពីឥដ្ឋឡើងទៅលើខ្នងភ្នំដែរ ។ ប្របនឹងមាត់ជណ្តើរ មានកូនអារាមតូចមួយដ៏មានកុដិស្អាតស្អំ នឹងមានតែព្រះសង្ឃមួយអង្គគង់នៅថែទាំរក្សាព្រះវិហារចេតិយដែលមាននៅលើខ្នងភ្នំនេះទាំងអម្បាលម៉ាន ។

**ភ្នំព្រះរាជទ្រព្យ** ! ដែលហៅថា **ភ្នំព្រះរាជទ្រព្យ**នេះ គឺសំដៅដល់តួភ្នំទាំងមូលមានទាំងវិហារ - ចេតិយ ព្រៃព្រឹក្សារួមជាមួយផង ។ ហេតុដូចម្តេចបានជាគេហៅទីភ្នំនេះទាំងមូលថាជា " **ភ្នំព្រះរាជទ្រព្យ** " ដូច្នេះ ? ត្រង់នេះយើងរកឃើញចំលើយដើម្បីជំរះការសង្ស័យនេះបានថា : ដោយទ្រង់យល់ថា ភ្នំនេះមិនខ្ពស់ពេក ហើយស្ថិតនៅក្បែរឧដុង្គជារាជវាំងស្រាប់ ព្រះរាជាសម័យនោះ ក៏ទ្រង់ចាត់អោយសាងព្រះចេតិយធំៗ នឹងមានចំលាក់លំអឆើតឆាយសំរាប់បញ្ចុះព្រះបរមអដ្ឋិ នឹងព្រះអដ្ឋិនៃព្រះរាជវង្សានុវង្ស ដោយចាត់សាងបូជនីយស្ថានទាំងនោះដោយកំលាំងព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ។ ហេតុនេះហើយ ទើបមានសន្មតនាមថា " **ភ្នំព្រះរាជទ្រព្យ** " ។ រហូតមកដល់គ្រាសព្វថ្ងៃនេះទៀត ក៏នៅតែមានការស្ថាបនាបន្ថែម នឹងការថែរក្សាទីកន្លែងនេះយ៉ាងខ្ជាប់ខ្ជួនដោយសារកំលាំងព្រះរាជទ្រព្យដែរ ។

រីឯសណ្ឋានភ្នំ នឹងទីតាំងនៃបូជនីយស្ថានទាំងឡាយនៅលើភ្នំនេះមានរបៀបរៀបចំដូចតទៅ : ទ្រង់ទ្រាយភ្នំទាំងមូល គឺវែង សណ្តូកពីជើងទៅត្បូង ជាជួរភ្នំមួយដ៏មានកំពូលខ្ពស់ត្រដែតជាងគេបីកន្លែង ដែលយើងសន្មតក្នុងនេះជាចំណុចសំគាល់បីគឺ ក - ខ - គ រាប់ពីខាងជើងទៅ ។ ត្រង់ចំណុច " ក " ខ្ពស់ជាងគេ មានជណ្តើរធ្វើពីថ្មបាយក្រៀមពេនពង់ដែលនិយាយរួចម្តងមកហើយ ឡើងទៅដល់លើដែលមានចេតិយធំៗបីគេហៅថា " **ចេតិយត្រៃត្រឹង្ស** " ។ កាលណាយើងឡើងតាមនេះទៅដល់ក្បាម នឹងប្រទះចេតិយធំមួយមុនគេ នៅខាងឆ្វេងដៃ ដែលជាចេតិយរបស់ព្រះករុណា **ព្រះខត្តិយកោដ្ឋ " ព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស "** ដ៏មានក្បាច់ក្បូរស្រស់បំព្រងនៅស្អាតបាតនៅឡើយ ។ យើងឡើង តាមជណ្តើរថ្មដដែល សសៀរតាមចំហៀងចេតិយនេះបន្តិចទៅទៀត ទើបដល់ទៅចេតិយពីរទៀត មានទំហំប៉ុនគ្នា គឺបាតក្រោមមួយជ្រុងៗមានប្រវែង ១៥ ម៉ែត្រ នឹងមានរបងដែកព័ទ្ធជុំវិញនៃចេតិយទាំងពីរនេះ បណ្តាចេតិយទាំងពីរ មួយខាងត្បូង ព្រះបាទសម្តេច **ព្រះនរោត្តម** ព្រះអង្គទ្រង់សាងឡើងនៅ គ.ស. ១៨៩១ ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃព្រះបាទសម្តេច **ព្រះអង្គឌួង** ជាព្រះវររាជបិតា ។

ចេតិយនេះ មានក្បាច់ក្បូរតាមបែបចេតិយធម្មតា គ្រាន់តែមានចំលាក់ប្លែកត្រង់កំពូលនឹងសង្ហារនៃព្រហ្មមុខបួន(១) តាមបែបរចនាខ្មែរតែប៉ុណ្ណោះ ។ ចេតិយខាងជើង ក៏មានទំហំប៉ុនគ្នាដែរ ប៉ុន្តែមានឆ្លាក់ជារូបដំរី លេចក្បាលធ្មោៗឡើងប៉ុនៗដំរីមែនទែន គេហៅថាចេតិយ ( **សាមពាន់** ) ចេតិយនេះ ព្រះបាទ **ជ័យជេដ្ឋា**កសាងឡើងតាំងពីគ.ស.១៦២៣

(១) : តាមក្បាច់រចនានៅអង្គរ គឺជាមុខលោកេស្វរៈ តែខ្មែរនិយមហៅថាមុខព្រហ្ម ។

ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃព្រះបាទស្រីសុរិយោពណ៌ ជាព្រះវររាជបិតា ។ ទិដ្ឋភាពនៅលើខ្នងភ្នំត្រង់នេះ គួរជាទីទស្សនាពន់ពេកណាស់ ព្រោះមើលទៅក្រោមឃើញផ្លូវនឹងផ្ទះអ្នកស្រុកព័ទ្ធជុំវិញភ្នំ មើលទៅខាងលិចឆ្ងាយទៅឃើញភ្នំស្អូងៗនៅឆ្ងាយសន្ធឹម ខាងកើតឃើញទឹកដៃ**ទន្លេសាប** នឹងភូមិអ្នកស្រុក**កំពង់លួង** ខាងជើងឃើញភូមិ **ចាំងចាស់** នឹងផ្សារ **ឧដុង្គ** នឹងខាងត្បូងឃើញថ្នល់ជាតិលេខ ៥ ទៅពីភ្នំពេញវែងលំលៃដូចជាលាតសន្ធឹងពួរមួយចង្វាយ ។ នៅផុតពីខ្នងភ្នំត្រង់នេះ មានជណ្តើរមួយចុះទៅចង្កេះភ្នំខាងជើងទៀត ប្រសិនជាយើងចុះទៅតាមនេះ យើងនឹងប្រទះឃើញចេតិយតូចចំទើរពីរទៀតនៅទន្ទឹមគ្នា មួយខាងកើត មួយខាងលិច គេហៅថា "**ចេតិយទន្ទឹម**" ។ ចេតិយទន្ទឹមខាងកើត ព្រះបាទសម្តេច **ព្រះអង្គចន្ទ** ទ្រង់សាងឡើងកាលពី គ.ស. ១៧៩៨ ដើម្បីបញ្ចុះព្រះអដ្ឋិនៃព្រះបាទសម្តេច **ព្រះអង្គអេង** ជាព្រះវររាជបិតា ។ សព្វថ្ងៃកំពូលបាក់ជ្រុះខ្លះទៅហើយ មួយទៀតខាងលិច គឺព្រះបាទ **ជ័យជេដ្ឋា** ទ្រង់សាងពី គ.ស. ១៦២៣ ដើម្បីបញ្ចុះព្រះអដ្ឋិនៃ **ព្រះសត្ថា** ជាព្រះបិតុលា ។ សព្វថ្ងៃនៅប្រែបចេតិយនេះ មានព្រះសង្ឃគង់នៅ ដោយសង់ជាកុដិសាលាតូចៗ ជានិវេសនដ្ឋាន ។

យើងឡើងត្រលប់ទៅកាន់ចេតិយ **ត្រៃត្រឹង្ស** ត្រង់ចំនុច " ក " វិញ រួចយើងចុះទៅតាមជណ្តើរដដែល ទៅខាងត្បូងឯបតាមចេតិយ នៃព្រះករុណាព្រះ **ខត្តិយភោជ** ហើយយើងមិនចុះជណ្តើរវែងមក កាន់ដីរាបវិញនៅឡើយទេ យើងដើរឆ្ពោះទៅត្បូងត្រង់ៗ ។ យើងចុះជណ្តើរស៊ីម៉ង់តិ៍បន្តិច យើងដើរលើដីទទេ តែដីត្រង់នេះមិនរាបស្មើទេ ចេះតែសំយុងចុះបន្តិចម្តងៗ ហាក់ដូចជានាំដំណើរយើងអោយចុះទៅកាន់ជ្រោះជ្រលងភ្នំ លើថ្មរកិបរកុបពុំរាបស្មើ ដំបូងយើងប្រទះគុហាតំរៀបជញ្ជាំងថ្មបាយក្រៀមតូចមួយ មានដំកល់ព្រះពុទ្ធរូបមួយអង្គ គេហៅថា "**ព្រះពុទ្ធរូបអ្នកតាជំទាវដែក**" ។ យើងសសៀរតាមចំហៀងខាងកើតនៃគុហារនេះយ៉ាងពិបាក ព្រោះផ្លូវចង្អៀតឆ្លងកាត់ក្បាលថ្មដ៏ខ្ពស់ៗ ហើយធំៗផង ។ ទៅមុខបន្តិចទៀត ដីកាន់តែចោតជ្រៅទៅ ។ ឆ្លងកាត់ជ្រលងនេះរួច ប្រទះឃើញមានគុហាតូចៗបីទៀត នៅជង្ហួរដង្ហែពីជើងទៅត្បូង ។ ដំបូងជាគុហាចាស់ធ្វើពីឥដ្ឋ ស៊ឹងតែរបេះចេញពីគ្នាទៅហើយ គុហានេះគេហៅថា "**ព្រះនាគ**" គឺដំកល់ព្រះពុទ្ធរូបនាគប្រក់ ។ តទៅទៀត គុហា **ព្រះកែវ** មានទំហំតូចជាងមុន គឺដំកល់ព្រះពុទ្ធរូបតូចល្មមមួយព្រះអង្គទៀត ។ នៅខាងត្បូងគេ គឺ "**គុហាព្រះគោ**" ដ៏ជាគុហាតូចទាបរងញ៉ាបស៊ឹងតែត្រឹមក្បាលមនុស្ស គ្របពីលើរូបគោមួយដេកនៅលើអាសនៈបែរមុខទៅអគ្នេយ៍ ។ ផុតពីនេះ ផ្ទៃដីខ្ចូងជ្រៅថែមទៅទៀត ។ ត្រង់ទីទំនាបនោះ មានជណ្តើរមួយចុះទៅផ្ទៃដីរាបឯផ្លូវថ្នល់នឹងមានជណ្តើរមួយទៀត ឡើងទៅកាន់ដីខ្នងភ្នំ ទួលខ្ពស់មួយកន្លែងទៀតជាចំណុច " ខ " ។ ត្រង់ចំនុច ‹‹ ខ ›› នេះ មានព្រះវិហារមួយធំជាងគេក្នុងបណ្តាបូជនីយស្ថានទាំងឡាយនៅភ្នំ **ព្រះរាជទ្រព្យ** គឺមានទំហំបណ្តោយ៥០ ម៉ែត្រ នឹងទទឹង ២៣,៤០ម បែរមុខឆ្ពោះមកទិសខាងជើង គឺចំផ្លូវដើរមកពីជើង ដែលយើងរាប់រៀបហូរហែមកហើយនោះ ។ បើយើងឈរមើលពីដីទំនាបមាត់ជណ្តើរខាងមុខ មុននឹងឡើងទៅកាន់ព្រះវិហារនេះ យើងនឹងឃើញទិដ្ឋភាពវិហារខ្ពស់ត្រដែតលេចចេញពីចុងឈើខ្នាន់ខ្នាប់ ។

ព្រះវិហារនេះមានភាពចំឡែកណាស់ បើយើងធៀបផ្ទឹមនឹងវិហារនានាទាំងអស់ក្នុងប្រទេស **កម្ពុជា** គឺទីមួយត្រង់បែរមុខឆ្ពោះទៅទិសខាងជើង ប្លែកពីព្រះវិហារទាំងឡាយដែលតែងតែបែរទៅខាងកើត ទីពីរត្រង់ជំបូលព្រះវិហារនេះ ពុំមានសណ្ឋានខ្ពស់ស្រួចងទន្ទាំប្រកបដោយជហ្វាដងក្ការដូចវិហារនានាទេ គឺបែរជារាងទាបទទាមានសណ្ឋានប្រហែលជំបូលផ្ទះប៉ិតទៅវិញ ។ ជញ្ជាំងព្រះវិហារធ្វើពីឥដ្ឋ បូកបាយអយ៉ាំងក្រាស់ ខាងក្នុងមានសសរចំនួន ២៦ ចែកជាបួនជួរបណ្តោយព្រះវិហារ ។ ពីរជួរជើងរៀបចំហៀងម្ខាង ៧ នឹងជើងរៀងមុខពីរ មានទំហំ ០,៦០ ម ឯពីរជួរកណ្តាលជាកន្ទោងសសរទីមួយៗ មានទំហំ ២ ម បើមនុស្សឈរកាងដៃបន្តគ្នា ៥ នាក់ ទើបអោបសសរនេះជុំ នៅក្នុងព្រះវិហារនេះទៀត

មានព្រះពុទ្ធរូប **មារវិជ័យ** មួយព្រះអង្គធំសំបើម គ្រាន់តែទទឹងភ្លៅទពីចុងម្ខាង ១០ ម កំពស់ពីបល្ល័ង្កទៅចុងមូលី ១១,៤០ម ហេតុនេះហើយបានជាចុងមូលីត្រូវខ្ពស់ទុលទៅដល់ដំបូលព្រះវិហារ បើគិតកំពស់នេះទៅនឹងខ្នាតបុរាណដែលនិយមរាប់ហត្ថព្រះសុគតសំរាប់វិន័យក្នុងព្រះពុទ្ធសាសនានោះ ឃើញថាមានកំពស់ ១៨ ហត្ថព្រះសុគតនេះឯង ។ អាស្រ័យដោយព្រះពុទ្ធរូបដ៏ធំអស្ចារ្យមានកំពស់ដល់ ១៨ ហត្ថយ៉ាងនេះហើយ ទើបអ្នកស្រុកសន្មតនាមព្រះវិហារនេះថា "**វិហារអដ្ឋារស**" មានន័យថា ដប់ប្រាំបី គឺសំដៅដល់ព្រះពុទ្ធរូបគង់កំពស់ ១៨ ហត្ថ ។ រីឯការប្លែកគួរអោយឆ្ងល់ត្រង់បែរមុខទៅជើង នឹងមានដំបូលទទានោះ បើតាមឯកសារនៅក្រុមជំនុំទំនៀមទំលាប់ស្តីអំពីប្រវត្តិព្រះវិហារនេះថា កាលពីរវាងសតវត្សទី ១៣ ឯនោះ ចិនបានមកស្លាបនាព្រះពុទ្ធរូបនេះឡើង ហើយធ្វើជាដំបូលប្រក់ឃុំគ្រងរក្សាព្រះពុទ្ធរូបនេះផង ។ ដូច្នេះ ចិនក៏រចនាដំបូលទាបទទាតាមរចនាចិន ហើយដំកល់ព្រះពុទ្ធរូបអោយបែរព្រះភក្ត្រទៅខាងជើង ឆ្ពោះទៅកាន់ប្រទេស **ចិន** តាំងពីកាលដំបូងនោះមក [(១)] ។ អាស្រ័យលើគំនិតថែទាំទុកដំណែលដើម ព្រះរាជាខ្មែរយើងក៏ព្រះអង្គពុំកែប្រែអោយបាត់ដានឡើយ ទោះបីជាព្រះអង្គបានជួសជុល រឺ សាងបន្ថែមទូវត្ថុព្រះវិហារនេះមួយលើកពីរលើកមកហើយក៏ដោយ ។

ផុតអំពីព្រះវិហារនេះទៅ យើងពុំអាចដើរលើខ្នងភ្នំនេះបណ្តោយទៅមុខទៀតកើតទេ ត្បិតព្រៃផ្សៃស្មុគស្មាញពេកដូចនេះ យើងត្រូវចុះថយមកដល់ជីរាបធម្មតាសិន រួចទើបឡើងទៅខ្នងភ្នំខាងកើតដែលជាជួរភ្នំតែមួយដដែល ប៉ុន្តែពេនបត់មកខាងកើតវិញ មានសណ្ឋានដូចមករ រឺ ក្រពើត្រកងកន្ទុយ រឺវាត់កន្ទុយពីក្រោយមកមុខវិញ ។ ខ្នងភ្នំនេះជាចំនុច " គ " ដែលមានជណ្តើរដីធម្មជាតិ នឹងមានតំរៀបដុំថ្មគ្រាន់តែកុំអោយរអិលនៅពេលមានភ្លៀងប៉ុណ្ណោះ ។ យើងដើរឡើងតាមជណ្តើរនេះ មិនខ្ពស់ជាងត្រង់ចំនុច " ខ " ទេ យើងនឹងប្រទះឃើញផ្លូវបែកជាពីរត្រង់មានស្រះជាអាងទឹកមួយនៅកណ្តាល គឺខាងស្តាំដៃបែកឡើងទៅកាន់វិហារមួយតូចល្មមរៀបចំបែប **ខ្មែរឥស្លាម** គេហៅថាវិហារ **តាសាន់** សង់ពីបាយអប្រក់ក្បឿង ។ ឯខាងឆ្វេងបែកទៅកាន់ "**ព្រះវិហារព្រះនិព្វាន**" ដ៏មានដំបូលបិតប្រក់ក្បឿងយ៉ាងចាស់ ជញ្ជាំងធ្វើពីបាយអយ៉ាងក្រាស់ តែចាស់ជ្រោបន្តិចទៅហើយ ។ ព្រះវិហារនេះបែរមុខទៅជើងដែរ មានទទឹង ៨ម បណ្តោយ ១១,២០ម ហើយនៅក្នុងនោះមានព្រះពុទ្ធរូប **បរិនិព្វាន** មួយព្រះអង្គ ព្រះកេសទៅកើត ព្រះបាទទៅខាងលិច បែរព្រះភក្ត្រទៅខាងត្បូង បណ្តោយព្រះអង្គពីព្រះកេសទៅត្បូង បណ្តោយព្រះអង្គពីព្រះកេសទៅដល់ចុងព្រះបាទប្រវែង ១០ ម៉ែត្រ ។ នៅពីមុខជាប់នឹងព្រះវិហារនេះមាន ចេតិយចាស់ជរាមួយដែលកសាងឡើងតាំងពី គ.ស.១៥៦៧ គឺព្រះបាទ **បរមិន្ទរាជា** ទ្រង់សាងសំរាប់បញ្ចុះព្រះអដ្ឋិនៃព្រះបាទ **ចន្ទរាជា** ជាព្រះវរាជបិតា ។

កាលណាយើងចុះពីខ្ពស់រាបនេះមកកាន់ដីទំនាបៗធម្មតា យើងនឹងប្រទះឃើញចេតិយតូច - ធំចាស់ៗ ជាច្រើនដេរដាស ខ្លះរុះធ្លាក់បាយអនឹងឥដ្ឋរដាច់រដោច នឹងមានដើមឈើដុះគ្របពីលើ តែមានខ្លះទៀតនៅគង់វង់ល្អនៅឡើយ ។ ចេតិយទាំងនេះ ជារបស់ព្រះរាជានឹងព្រះរាជវង្សានុវង្សពីមុនៗមក ។

ដូចនេះ សរុបសេចក្តីបានដូចតទៅ គឺឈ្មោះភ្នំដែលហៅថា "**ភ្នំព្រះរាជទ្រព្យ**" នោះ ដោយសារជាទីដែលព្រះរាជាតាំងពីដើមមកទ្រង់ទុកជាបូជនីយស្ថានផ្ទាល់ព្រះអង្គ នឹងរាជវង្សានុវង្សព្រះអង្គផង ដូចមានការរាប់រៀបពីចេតិយនីមួយៗ ដែលជាសំខាន់ៗជាងគេ នៅលើភ្នំនេះរួចមកហើយស្រាប់ ។ ឯឈ្មោះព្រះវិហារថា "**វិហារអដ្ឋារស**" នោះ គឺសំដៅដល់ព្រះវិហារដែលមានដំកល់ព្រះពុទ្ធរូបកំពស់ ១៨ ហត្ថនោះឯង ។

(១) : សូមអានរឿងនេះនៅក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ ៥ របស់ពុទ្ធសាសនាបណ្ឌិត្យ ។

## សញ្ញាសំគាល់




1 ចេតិយ **សាមពាន់** ( ព្រះបាទ **ជ័យជេដ្ឋា** សាងពី គ.ស. ១៦២៣ )

2 ចេតិយព្រះបាទ **នរោត្តម** សាងពី គ.ស. ១៨៩១ ។

3 ចេតិយព្រះករុណាខត្តិយ ( **ព្រះមុនីវង្ស** ) សាងពី គ.ស. . . . ។

4 ព្រះវិហារ **អដ្ឋារស**

5 ព្រះវិហារ **ព្រះនិព្វាន**

6 ចេតិយព្រះបាទ **បរមិន្ទរាជា** ( សាងពី គ.ស. ១៥៦៧ )

7 វិហារ ពួក **តាសាន់** ( ខ្មែរ **ឥស្លាម** កាន់សីលប្រាំ )

8 ចេតិយ **ឧត្តម** ( ខាងកើតព្រះបាទ **អង្គចន្ទ** សាងពី គ.ស. ១៥៦៧ )

9 ចេតិយ **ឧត្តម** ( ខាងលិចព្រះ **ជ័យជេដ្ឋា** សាងពី ១៦២៣ )

10 គុហាអ្នកតា **ដំបងដែក**

11 គុហា **ព្រះនាគ** ( ពុទ្ធរូប **នាគប្រក់** )

12 គុហា **ព្រះកែវ** ( ព្រះពុទ្ធរូប )

13 គុហា **ព្រះគោ** ( រូបគោដេក )

ឯសញ្ញាមូល ០ ដូចនេះ ជាចេតិយរបស់ព្រះរាជវង្សដែលកសាងនៅលើភ្នំនេះដែរ ។ ឯចេតិយដែលនៅខាងក្រោមទាំងប៉ុន្មាន ឥតចែងក្នុងនេះទេ ។

# ជាងមិនកើត បន្ទោសដែក

# ស្តាយកេរចាស់

ស្តាយកេរបុរាណលោកខំសាង ទុកជាតំណាងវប្បធម៌ខ្មែរ
ឥឡូវរេចរឹលទៅហែៗ ព្រោះតែស្រុកទេសកើតចំបាំង ។
កេរខ្លះវិនាសដោយធម្មជាតិ ដោយធាតុអាកាសប្រែប្រួលខ្លាំង
កេរខ្លះវិនាសព្រោះចោរខ្មាំង វាតាំងជីកគាស់កាយរំលើង ។
ស្តាយជនចិត្តចោរសោគ៌និត គួចគិតតែលួចតាមទំនើង
បាត់ជាតិបាត់សាសន៍ធ្វើមិនដឹង តែប្រឹងតែលួចលក់យកប្រាក់ ។
ស្តាយកេរដូនតាការខ្វះថែ យូរឆ្នាំយូរខែក្តៅត្រជាក់
នៅដោយកន្លែងគ្មានធ្នើថ្នាក់ ធូលីហុយដាក់កណ្តុរកាត់ ។
ស្តាយបាត់គតិប្រជាប្រិយ៍ ទំនៀមប្រពៃមានច្រើនក្តាត់ ។
រស់រៀងតំណគតាមមាត់ ចាស់គាត់ចេះចាំតាមសំនួន ។
ឥឡូវចាស់ស្លាប់បាត់ស្ទើរអស់ យកទាំងរបស់ប្រចាំខ្លួន
ចំណេះចំណាំគ្មានក្នុងក្បួន ចាស់ចាំដោយខ្លួនមិនបានចារ ។
ស្តាយភ្លេចចំរៀងសៀងពិរោះ ស្តាយព្រោះរបាំល្បែងប្រជា
ក្មេងក្រោយមិនស្គាល់ទាល់ប្រាជ្ញា យកល្បែងពាលាមកជំនួស ។
ស្តាយព្រៃព្រឹក្សាលតារល្វិ ឈើល្អបុរាណបានដាក់ឈ្មោះ
ប្រភេទផ្សេងៗគ្មានចន្លោះ ស្តាយបាត់ដើមអស់សល់តែនាម ។
ស្តាយឈើស្តាយព្រៃចាស់លោកដាំ ទុកជាដំណាំក្នុងអារាម
កាលមានចាស់នៅចាស់លោកហាម ពេលអត់ចាស់ភ្លាមក្មេងបានដៃ ។
ស្តាយមិនបានដាំចាំតែកាប់ ស្តាយចាប់ច្រើនជាងចិញ្ចឹមត្រី
ទឹកសាបសមុទ្រមិនយូរថ្ងៃ គង់ក្ស័យផុតពូជមិនសល់ដាន ។
ឯត្បូងរតនៈមានតំលៃ ក៏គង់មានថ្ងៃអន្តរធាន
ព្រៃក្លាយជាវាលរហោស្ថាន គួរខ្មែរគិតអានគ្រប់អាត្មា ។
អស់ព្រៃអស់សត្វបាត់ទាំងទឹក ខ្វះហូបល្ងាចព្រឹកខ្វះមច្ឆា
ព្រៃទន្លេស្ទឹងបឹងជលសា ប្រែជារីងស្រកខកខានខែង ។

ស្ដាយទ្រព្យវប្បធម៌ចាស់កសាង ទុកជាភស្តុតាងអោយជាក់ស្ដែង
ជាគោលចារឹកប្រាប់ក្មេងៗ អោយស្គាល់កន្លែងដំណែលចាស់ ។
ឥឡូវបាត់អង្គបង់ទួលតាំង បាត់ប្រាង្គព្រះធាតុមានចំណាស់
ប្រាសាទតូចធំធានីចាស់ សល់ខ្លះខូចខ្លះខ្វះរមណីយ៍ ។
ស្ដាយកេរ្តិ៍កាលណោះខ្ពស់ជាងមេឃ ឥឡូវចុះទាបពេកទាបស្មើដី
ខ្មែរអើយគួរខ្មាសសាសន៍ដទៃ ហេតុអ្វីមិនស្ដាយកេរដូនតា ។
ស្ដាយនៅក្នុងចិត្តជិតកង្វល់ ចំងល់ជាទុក្ខក្នុងឱរា
ស្ដាយប្រាណប្រែចាស់ក្រាស់វស្សា រស់មិនបានការដូចបុរាណ ។
ស្ដាយធ្វើមិនបានដូចបំណង ចិត្តប៉ងចង់ធ្វើធ្វើមិនបាន
ស្ដាយកើតមកហើយរស់រំខាន រស់រួចតែប្រាណគ្មានកំនើត ។
នេះចាស់ស្ដាយចាស់របស់ចាស់ ស្ដាយណាស់ការកេរចាស់បង្កើត
ការក្មេងធ្វើតាមមិនសូវកើត ការកើតបាត់ពោមក្នុងគ្រានេះ ។

ដោយលោក ឃី ធន់



# បរិដ្ឋានបរិយាកាស

## Environnement atmosphérique

*ដើម្បីពង្រីកចំនេះដឹងផ្នែកវិទ្យាសាស្ត្រសង្គម គណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ មានសេចក្តីរីករាយផ្ញើអត្ថបទខាងក្រោមនេះទុកជាទ្រព្យសម្បត្តិរបស់សមាជិក សមាជិកា*

សព្វថ្ងៃនេះ ប្រជាពលរដ្ឋកម្ពុជាភាគច្រើន មានចំងល់ជាខ្លាំងទៅលើការប្រែប្រួលធាតុអាកាស ។ គេតែងសួរនាំគ្នាថា ហេតុអ្វីបានជាអាកាសធាតុកាន់តែក្តៅឡើងៗពីមួយឆ្នាំទៅមួយឆ្នាំដូច្នេះ ? ហេតុអ្វីបានជាមានទឹកជំនន់កាចសាហាវម្ល៉េះ ? ខុសប្លែកពីសម័យដូនតា ។

ដើម្បីយល់ដឹងពីមូលហេតុនៃភាពរាំងស្ងួតរាំងរ៉ៃ និងភាពលិចលង់ដោយទឹកជំនន់ រឺទឹកជន់ខុសប្លែកនាឆ្នាំកន្លងទៅ យើងត្រូវសិក្សាពីបរិយាកាស (atmosphère) ជាមុនសិន ។ ក្នុងប្រព័ន្ធឃោសនា គេនិយាយថា យើងត្រូវការពារ រឺថែរក្សាបរិដ្ឋានបរិយាកាសអោយបានស្អាតស្អំល្អ ។ តើត្រូវធ្វើដូចម្តេច ? នរណាជាអ្នកធ្វើអោយបរិដ្ឋានបរិយាកាសកខ្វក់ រឺខូចខ្ទេចខ្ទីអស់ ?

ខាងក្រោមនេះជាចំលើយដោះស្រាយចំងល់ :

ដំបូងយើងត្រូវយល់ **អ្វីទៅដែលហៅថា បរិយាកាស ?**

បរិយាកាស រឺ មណ្ឌលខ្យល់ គឺជាស្រទាប់ឧស្ម័នដែលគ្របដណ្តប់ជុំវិញផែនដី ។

រាល់ជីវិតមនុស្ស សត្វតូច - ធំ សត្វល្អិត ព្រៃព្រឹក្សាលតាវល្លិ ដែលរស់នៅលើផែនដី គឺអាស្រ័យដោយការគាំពារនៃមណ្ឌលខ្យល់នេះឯង ។

បរិយាកាស កើតឡើងដោយស្រទាប់ឧស្ម័នពីរ ដែលមានឈ្មោះថា ៖

១- មណ្ឌលអាកាសចល់ (troposphère)

២- មណ្ឌលអាកាសស្ងប់ (stratosphère)

## I - មណ្ឌលអាកាសរចល់ La troposphère

មណ្ឌលអាកាសរចល់នៅជាប់និងផែនដី មានកំពស់ប្រមាណ ១០ គម. ជាមធ្យម មានកំពស់ពី ១៦ ទៅ ១៧ គម. នៅអេក្វាទ័រ និងពី ៦ ទៅ ៨ គម. នៅប៉ូល (១) ។

ពីផែនទីទៅ រឺពីលើកប៉ាល់ហោះ គេឃើញផ្ទៃមេឃខៀវ ។ ត្រង់នេះហើយ គឺជាមណ្ឌលអាកាសរចល់ ។ នៅក្នុងមណ្ឌលនេះ គេឃើញពពកអណ្ដែតនឹងថ្កល់ រឺរសាត់តាមខ្យល់ ។ ពពកទាំងនេះវាដេរដាសនោះកើតមកពីអ្វី ? គឺកើតមកពីចំហាយទឹក ។

កាលណាព្រះអាទិត្យចែងចាំងរស្មីទៅលើផ្ទៃទឹកសមុទ្រ កាំរស្មីនោះបានកំដៅទឹកយ៉ាងខ្លាំង បង្កើតបានជាចំហាយទឹកហួតឡើងខ្ពស់ទៅៗក្នុងវេហាស៍ ។ នៅពេលប៉ះខ្យល់ត្រជាក់ ( airfroid ) ចំហាយនោះបានប្រែក្លាយជាដុំពពកដែលយើងឃើញរសាត់អណ្ដែតនៅពេលមានខ្យល់ រឺនៅពេលមេឃងងឹត ។ កំលាំងធម្មជាតិមួយទៀតដែលមានក្នុងមណ្ឌលអាកាសរចល់ គឺខ្យល់ ។ ខ្យល់បក់ជាត់ពពកមកប៉ះភ្នំ រឺព្រៃឈើស្រោង បង្កើតបានជាភ្លៀង ។ កាលណាមានខ្យល់ខ្លាំង កំលាំងខ្យល់បោកបំបែកដុំពពកធំៗអោយបែកខ្ញែកជាទឹកភ្លៀងធ្លាក់ចុះពាសពេញបានជាច្រើនកន្លែង ។

## II - មណ្ឌលអាកាសស្ងប់ La stratosphère

គឺជាស្រទាប់ឧស្ម័នស្ថិតនៅលើមណ្ឌលអាកាសរចល់ ដែលមានកំពស់ប្រមាណ ៤០ គ.ម ។ នៅបាតមណ្ឌលអាកាសស្ងប់នេះមានសមាសធាតុ ( composé ) ម្យ៉ាងហៅថា ស្រទាប់អូសូន ( Ozone ) ដែលជារនាំងបាំងមិនអោយកំដៅព្រះអាទិត្យជះខ្លាំងពេកមកលើផែនដី ។

កាំរស្មីស្វាយអ៊ុលត្រា ( rayon ultra-violets ) ចេញពីពន្លឺថ្ងៃបានធ្វើអោយអុកស៊ីសែន ( oxygène ) ក្លាយទៅជាអូសូន ។

សមតាបិរវន្ត ( équilibre stable ) រវាងកាំរស្មីដែលបញ្ជូនត្រលប់វិញដោយស្រទាប់អូសូន នឹងកាំរស្មីជះមកលើផែនដី បានបង្កើនជីវិតនៅលើពិភពលោក បានសុខស្រួលជាយូរអង្វែងឆ្នាំមកហើយ ទោះជាជីវិតនោះស្ថិតនៅក្នុងតំបន់ អេក្វាទ័រ ត្រូពិច ក្បែរត្រូពិច និងត្រជាក់ ។ ប៉ុន្តែ ចាប់ពីបច្ចុប្បន្នកាលនេះតទៅ សមតាបិរវន្តនឹងត្រូវរលំរលាយជាបណ្ដើរៗ ព្រោះតែមនុស្សលោក នាំគ្នាបំផ្លាញដោយឧស្ម័នកាបូនិច និងអុកស៊ីតផ្សេងទៀត ។ សារជាតិដ៏ចង្រៃនេះ កំពុងតែបំផ្លាញអូសូនអោយកាន់តែខ្សោយទៅៗ ស្តើងទៅៗ នាំអោយអូសូនមិនមានកំលាំងទប់កំដៅព្រះអាទិត្យបានគត់មត់ល្អ ( appauvrissement de la couche d'ozone ) ។

## តក់ៗ ពេញបំពង់

(១) : សូមស្វែងយល់បន្ថែមពី អេក្វាទ័រ និង ប៉ូល ។




សូមលោកអ្នកអានគិតបន្តិចមើល តើនៅលើពិភពលោកសព្វថ្ងៃនេះ មានគ្រឿងចក្រកំពុងបញ្ចេញឧស្ម័នកាបូនិចប៉ុន្មាន ? សូមរាប់តាំងពីឡានធំតូច រោងចក្រ កប៉ាល់ទឹក កប៉ាល់ហោះ គ្រាប់បែក យានអាវកាសដែលទំលុះស្រទាប់អូសូនហួសទៅទៀត ។ ក្រៅពីនេះការបំផ្លាញ និងដុតព្រៃឈើ និងកាកសំណល់ផ្សេងៗ នាំអោយធាតុអាកាសប្រែប្រួលអោយកាន់តែក្តៅឡើងៗ ។

អ្នកការពារបរិដ្ឋាន ស្រែករំពាវនាវយ៉ាងណាក៏ដោយ ក៏មនុស្សមិនយល់តាមឡើយ ។ គេដុត គេបំផ្លាញដដែល ។

**សូមសង្កេត** - តើឃើញអ្វីខ្លះនៅលើគំនូរបំព្រួញខាងលើនេះ ?

* ព្រះអាទិត្យចាំងជះកាំរស្មីមកលើ

១- សមុទ្រ បង្កបង្កើតបានជាចំហាយទឹក ពពក ភ្លៀង ។

២- ស្រទាប់អូសូនដែលចាត់ទុកជារនាំងបាំងមិនអោយកាំរស្មីស្វាយអ៊ុលត្រា ( rayons ultra-violets ) ទាំងអស់ចាំងមកដល់ផ្ទៃដី ព្រោះកាំរស្មីនេះអាចបំផ្លាញជីវិតសត្វលោកបាន ។

**សំនួរ** : តើយើងមើលឃើញស្រទាប់អូសូនដែរទេ ?

**ចំលើយ** : មិនឃើញទេ ព្រោះវាជាឧស្ម័ន ។ គំនូរបំព្រួញនេះគ្រាន់តែសំរាប់បង្ហាញប៉ុណ្ណោះ

* **សូមជញ្ជឹងគិត** : យន្តហោះប៊ើកបរវិលជុំវិញសព្វថ្ងៃ ហោះហើរកំពស់ ៩ ទៅ ១០ គ.ម ដើម្បីអោយផុតពពក និងភ្លៀង ។ តើឧស្ម័នចេញពីម៉ាស៊ីនប្រតិកម្ម ( moteur à réaction ) ទៅណា ?

# ទឹកជំនន់ រឺ ទឹកជន់



ដើម្បីយល់ដឹងពីមូលហេតុទឹកជនលិចស្រុកភូមិដែលបំផ្លាញអស់ផលដំណាំ សត្វពាហនៈ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតនោះ ( ទឹកជន់ឆ្នាំ ១ ៩ ៩ ១ )យើងគួរស្វែងយល់ពីសារៈសំខាន់របស់ព្រៃឈើលើបរិយាកាសជាមុនសិន ។

## សារៈសំខាន់របស់ព្រៃឈើលើបរិយាកាស

ព្រៃឈើជាទ្រព្យសម្បត្តិធម្មជាតិដ៏សំខាន់របស់មនុស្សជាតិ ព្រោះព្រៃឈើអាចផ្តល់ផលប្រយោជន៍ច្រើនយ៉ាងដល់មនុស្ស អាចអោយមនុស្សមានជីវភាពរស់នៅ និងជៀសវាងគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ ៖

*១- ព្រៃឈើរាំងការពារទឹកជំនន់*

ទឹកជំនន់កើតមកដោយសារភ្លៀងធ្លាក់ជោគជាំផ្ទួនៗឥតឈប់ឈរនៅលើតំបន់ណាមួយ ។ តំបន់ណាដែលព្រៃឈើត្រូវរិចរិល រឺតំបន់ដែលគ្មានព្រៃឈើ បរិយាកាសធម្មជាតិគ្មានស្ថេរភាព ។ ពេលខ្លះក្តៅខ្លាំង ពេលខ្លះត្រជាក់ខ្លាំង រឺពេលខ្លះមានភ្លៀងធ្លាក់ខ្លាំង រឺពេលខ្លះគ្មានភ្លៀង ។ ក្នុងពេលមានភ្លៀងធ្លាក់ខ្លាំង តំបន់នេះងាយទទួលរងនូវទឹកជំនន់បានយ៉ាងលឿនបំផុត ព្រោះនៅពេលមានភ្លៀងធ្លាក់ ដីហាប់ណែនដោយសារទំងន់តំណក់ទឹកភ្លៀង ហើយទឹកពុំមានលទ្ធភាពជ្រាបចូលទៅក្នុងដី ហើយបាចសាចឆ្ពោះទៅតំបន់ទំនាប បង្កើតបានជាធារទឹកដ៏ធំ ។ ដោយគ្មានព្រៃឈើទប់ស្កាត់ផងនោះ ចរន្តទឹកហូរកាន់តែខ្លាំងឡើងៗ ហើយបរិមាណទឹកកាន់តែកើនឡើងឥតឈប់ឈរ បង្កើតបានជាទឹកជំនន់ជន់លិចភូមិស្ថាន និងបង្កវិនាសកម្មដ៏ធំធេងដល់ទ្រព្យសម្បត្តិ និងអាយុជីវិតរបស់មនុស្ស ។

*២- ព្រៃឈើរាំងកាត់បន្ថយការហូរច្រោះ ទឹកជំនន់ និងរក្សានិយ័តភាពប្រភពទឹក*

នៅពេលមានភ្លៀងធ្លាក់ ដោយសារគំរបព្រៃ ( បណ្តុំកន្ទ្បោមស្លឹក ) បានស្កាក់ទឹកភ្លៀងមួយចំនួនសំរាប់ការភាយអោយទៅអាកាសវិញ តាមរយៈការភាយហួតចំហាយទឹកដោយកំដៅ ហើយមួយចំនួនទៀតគំរបព្រៃបានបន្ថយទំងន់តំណក់ទឹកភ្លៀងកុំអោយធ្លាក់ពេញទំហឹងទៅលើផ្ទៃដី ។ រុក្ខជាតិតូចៗ កំរាលស្លឹក ស្រទាប់ពុកផុយ មីក្រុប សត្វនៅក្នុងដី ជន្លេនជាដើម និងប្រព័ន្ធកន្ទ្បោមឫសធ្វើអោយដីធូរស្រួលបឺតទឹកចូលបានយ៉ាងងាយដោយសន្សឹមៗ ហាក់បីដូចជាក្រដាសស្រូបផ្តិតទឹក ។ ប្រព័ន្ធទាំងអស់ខាងលើនេះគឺគ្រឹះសំរាប់ការពារការហូរច្រោះ ។ ដើមឈើគឺជារបាំងដ៏រឹងមាំក្នុងការកាត់

បន្ថយល្បឿនទឹកជំនន់អោយមានភាពជាមធ្យមដោយមិនអោយមានភាពកាចសាហាវពេក ដែលអាចប៉ះពាល់ដល់អាយុជីវិតមនុស្ស សត្វ និងរបរកសិកម្ម ។

ដោយដីព្រៃមានមមោតច្រើន ស្រទាប់ពុកផុយនៅលើផ្ទៃដី និងនៅក្រោមដី ព្រមទាំងប្រព័ន្ធឫសបានផ្តល់នូវភាពសើមជានិច្ច ហើយបង្កើតប្រភពទឹកជាអចិន្ត្រៃយ៍ដល់ជ្រោះជ្រលងជងអូរដោយជ្រាបហូរជាស្ទឹង ព្រែក ប្រឡាយសំរាប់ជួយសំរួលដល់ការប្រកបរបរកសិកម្មរបស់មនុស្សគ្រប់តំបន់ ។

ការសិក្សាស្រាវជ្រាវរបស់ស្ថានីយ៍ស្រាវជ្រាវព្រៃឈើរបស់ប្រទេសវៀតណាមអំពីការហូរច្រោះ បានបង្ហាញអោយឃើញថា ៖

ក្នុងកំរិតបរិមាណទឹកភ្លៀង ១.៧០០ ម.ម ឆ្នាំ សីតុណ្ហភាពមធ្យម ២២ អង្សាសេ សំណើមមធ្យម ៨០ភាគរយ និងចំណោទ ១៦ ភាគរយគេសង្កេតឃើញដូចតារាងខាងក្រោម ៖

| ប្រភេទដី | បរិមាណដីហូរច្រោះរិចរិល t / ha ឆ្នាំ |
|---|---|
| ដីព្រៃធម្មជាតិ | 1,003 |
| ដីទំនេរ ( ដីគ្មានព្រៃ ) | 123,974 |



## ៣ - ព្រៃឈើកាត់បន្ថយល្បឿនខ្យល់ និងថាមពលកំដៅ

ព្រៃឈើជារបាំងការពារខ្យល់ព្យុះ ។ ខ្យល់ត្រូវបាត់បង់លក្ខណៈទាំងកំលាំង ទាំងទិសដៅតិចរឺច្រើន អាស្រ័យដោយសណ្ឋានព្រៃតាមដង់ស៊ីតេព្រៃ និងទិសដៅ ត្រង់រឺបញ្ឆិត ។ ខ្យល់ដែលបក់មកប៉ះលើព្រៃឈើមួយភាគត្រូវបានតំរបព្រៃទប់បន្ថយ មួយភាគរំលងតំរប់ព្រៃ និងមួយភាគទៀតទំលុះចូលទៅក្នុងព្រៃ ។ កាលណាដង់ស៊ីតេកាន់តែធំល្បឿនខ្យល់ក៏បាត់បង់ឆាប់រហ័សដែរ ។ ព្រៃឈើដែលដុះមានសណ្ឋានភាពជាល្វែងៗ ច្រើនជួរ កាត់ទទឹងចំពីមុខទិសខ្យល់ធ្វើអោយល្បឿនខ្យល់ដែលឆ្លងកាត់ព្រៃនេះ ត្រូវថយចុះពី ៣០ ទៅ ៤០ភាគរយនៃល្បឿនដើមរបស់វា នៅលើចំងាយដីដែលមានប្រវែងស្មើ ១០ ដងនៃកំពស់ព្រៃ បន្ទាប់ពីឆ្លងកាត់ព្រៃបានចំងាយ ៤០ នៃកំពស់ព្រៃនោះ ល្បឿនខ្យល់មានកំរិតកើនឡើងស្មើនិងល្បឿនដើមរបស់វា ។

ចំណែកឯពន្លឺថ្ងៃដែលជះទៅលើតំរបព្រៃមួយភាគបួននៃពន្លឺថ្ងៃត្រូវចំណាំងផ្លាតទៅលើវិញតាមរយៈតំរបព្រៃ (បណ្ដុំកន្ទ្បោមស្លឹក) ពីរភាគបួននៃពន្លឺថ្ងៃត្រូវតំរបព្រៃស្រូបយក ដើម្បីធ្វើសកម្មភាពរស្មីសំយោគ និងដកដង្ហើម ហើយមួយភាពបួនបានចុះចូលទៅដល់ផ្ទៃដីព្រៃ ធ្វើអោយតំបន់នោះពុំសូវក្ដៅ ។

សីតុណ្ហភាពក្នុងព្រៃនៅរដូវប្រាំងទាបជាងអាកាសធាតុនៅខាងក្រៅពី ៨ - ១០ អង្សាសេ និងក្នុងរដូវរងារសីតុណ្ហភាពនៅក្នុងព្រៃខ្ពស់ជាងអាកាសធាតុនៅខាងក្រៅពី ១ ទៅ ២ អង្សាសេ ។

សរុបមកព្រៃឈើមានសារៈសំខាន់ណាស់ វាជារបាំងការពារខ្យល់ព្យុះ កាត់បន្ថយល្បឿនទឹកជំនន់ ការហូរច្រោះដី ផ្ដល់ប្រភពទឹកមិនចេះរីងស្ងួត និងផ្ដល់ជីរជាតិសំរាប់ផលដំណាំកសិកម្មដល់ប្រជាកសិករ ព្រមទាំងអាចកាត់បន្ថយថាមពលកំដៅដែលជាហេតុធ្វើអោយអាកាសធាតុស្ថិតនៅក្នុងតុល្យភាពជានិច្ច ។ ដូចនេះយើងទាំងអស់គ្នាត្រូវតែខិតខំការពារព្រៃឈើ ការពារបរិដ្ឋាន អោយបានល្អប្រសើរ ហើយជាពិសេសយើងត្រូវដាំបន្ថែមអោយបានច្រើនថែមទៀត ឆ្លើយតបទឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលផង និងដើម្បីជីវភាពរស់នៅប្រកបដោយសុភមង្គលរបស់យើងផង ។





# ការអប់រំ & គរុកោសល្យ

## អភិវឌ្ឍន៍ធនធានមនុស្ស

**Le développement des ressources humaines**

បច្ចុប្បន្នកាលនេះ យើងបានឮ បានអានពាក្យ ធនធានមនុស្ស ។ គេច្រើននិយាយថា កសាងធនធានមនុស្ស រឺ អភិវឌ្ឍធនធានមនុស្ស ។ តើធនធានក្នុងទីនេះ មានន័យដូចម្ដេច ?

ដើម្បីស្វែងយល់អោយបានស៊ីជំរៅបញ្ញត្តិនេះ ខ្ញុំសូមសាកល្បងបកស្រាយដូចតទៅ ៖

ធនធាន តាមន័យធម្មតា ប្រែថា ទ្រព្យសម្បត្តិ រឺភោគទ្រព្យ ( Richesses ) ។ ដូចនេះ មនុស្សចាត់ទុកជាទ្រព្យសម្បត្តិ រឺជាកំលាំងរបស់ប្រជាជាតិមួយ ។ គេសង្កេតឃើញថា ប្រទេសនីមួយៗ មានភោគទ្រព្យ រឺ ធនធានពីរបែបគឺ ៖

**1. ធនធានធម្មជាតិ** **( Ressources naturelles ) :**

គឺជាធនធានកើតឡើងមកឯងមិនមាននរណាប្រឹងបង្កើតឡើយ ដូចជា រ៉ែមាស ត្បូង ពេជ្រ ប្រេងកាត និងរ៉ែលោហធាតុផ្សេងៗ ទៀត ។ ក្រៅពីនេះ មានព្រៃព្រឹក្សា ម្រឹគម្រឹគា ទន្លេ បឹងបួរ សមុទ្ទ ត្រី ។ល ។ ធនធាននេះ ជាសក្ដានុពលរបស់ប្រទេស ព្រោះវាអាចធ្វើអោយប្រទេសសម្បូរសប្បាយរីកចំរើនបាន កាលណាគេធ្វើអាជីវកម្មត្រឹមត្រូវតាមច្បាប់បញ្ញាតិរបស់រដ្ឋ ។

**2. ធនធានមនុស្ស :**

គឺជាប្រជាពលរដ្ឋ ដែលជាកំលាំងសំរាប់កសាង និងការពារប្រទេស ។

ការកសាងធនធានមនុស្ស គឺការបណ្ដុះបណ្ដាលអប់រំមនុស្សអោយបានជាកំលាំងកាយ នឹងបញ្ញា ព្រមទាំងចរិយា ដើម្បីក្លាយជាពលរដ្ឋល្អ មានថាមពលក្លៀវក្លាសំរាប់កសាងជាតិ ព្រោះជាភាគព្វកិច្ចរបស់មនុស្សគ្រប់រូប ។

យើងសួរថា សព្វថ្ងៃនេះ សាលារៀនគ្រប់ភូមិសិក្សា បានបំពេញតួនាទីជាអ្នកកសាងពលរដ្ឋអោយក្លាយជាកំលាំងប្រទេសបានកំរិតណាហើយ ។ មតិត្រូវបានបែកជាពីរ : **មតិទីមួយយល់ថា** ការបង្ហាត់បង្រៀនយុវវ័យអោយមានចំនេះដឹង មានវិជ្ជាជីវៈ មានសីលធម៌ ជាភារកិច្ចរបស់សាលារៀន ។ យុវជន យុវនារីចេញពីសាលា ជាកំលាំងរបស់ប្រទេស ។ **មតិទីពីរយល់ថា** ការបណ្ដុះបណ្ដាលនៅតាមសាលារៀនមិនអាចច្នៃមនុស្សអោយទៅជាកំលាំងប្រទេសបានទេ ព្រោះអ្នកដែលនឹងត្រូវទទួលបង្ហាត់បង្រៀន ត្រូវមានសុខភាពល្អបរិបូរណ៍ផង មានកំលាំងពលំសមស្របអាចទទួលការអប់រំបានផង ។ ដូចនេះ កត្តាសុខភាព និងចំនីអាហារ ( la santé et la nutrition )ជាកត្តាទីពីរ ។ សាលារៀនមានតួនាទីអប់រំបណ្ដុះបណ្ដាលយុវវ័យក៏ពិតមែនហើយ តែអប់រំអ្នកឈឺ អ្នកខ្វះម្ហូបអាហារបរិភោគ តើលទ្ធផលនៃការអប់រំបានកំរិតណា ?

សូមក្រឡេកមើលប្រជាពលរដ្ឋកម្ពុជាយើងសព្វថ្ងៃ ដែលរស់នៅជនបទ និងនៅទីក្រុង ។ តើអ្នកមានសុខភាពបរិបូរណ៍ និងមានម្ហូបអាហារគ្រប់គ្រាន់ មានចំនួនប៉ុន្មានភាគរយ ។ កូនចៅអ្នកទាំងអស់នោះ មានប៉ុន្មានភាគរយ ។ ប្រទេសក្រដូចប្រទេសកម្ពុជាសព្វថ្ងៃ មិនអាចជៀសផុតពីទុក្ខភាព ។ ជំងឺគ្រប់បែបយ៉ាងតែងតែយាយី ព្រោះម្ហូបអាហារមិនគ្រប់គ្រាន់ និងខ្វះអនាម័យ ។ អ្នកអប់រំបានដឹងច្បាស់ហើយពីមូលហេតុចំបងនៃអវត្តមានដ៏សន្ធឹកសន្ធាប់នៃសិស្ស ពីការបោះបង់ការសិក្សា ពីការរៀនត្រួតថ្នាក់ ។ល ។ តើអត្រាមានប៉ុន្មាន ?

ភាពទីទ័លក្រធ្វើអោយប្រជាពលរដ្ឋស្គាំងស្គមមិនសូវមានកំលាំងកំហែងទប់ទល់ជំងឺ ។ កង្វះម្ហូបអាហារមានជីវជាតិមានតាំងពីវ័យនៅកុមារ រហូតដល់ចាស់ជរា ។ យើងអាចប្រដូចការអត់ឃ្លានទៅនឹងកង់ដែលវិល ( Cycle de la faim ) ។ សូមពិនិត្យគ្រួសារមួយ ។ យើងមិនអាចដឹងថាមានគ្រួសារប៉ុន្មានទេដែលមានស្ថានភាពប្រហាក់ប្រហែលគ្នាបែបនេះ ។ គ្រួសារមួយមានកូនបីនាក់ហើយ ( កូនពីរឆ្នាំមួយ ) ។ ឥឡូវនេះ ប្រពន្ធចាប់មានគភ៌ទៀត ។ យើងដឹងហើយថាកូនក្នុងផ្ទៃម្ដាយត្រូវការចំនីអាហារអោយបានគ្រប់គ្រាន់ និងមានជីវជាតិ ។ តើម្ដាយអាចផ្ដល់អោយបានទេ បើខ្លួនឯងរកអ្វីទទួលទានអោយបានឆ្អែតពុំបានផងនោះ ? កូនកើតមកមិនមានទំងន់តាមនិយាមពេទ្យ ។ ម្ដាយមិនមានទឹកដោះអោយកូនបៅគ្រប់គ្រាន់ដោយកង្វះអាហារ ។ ដល់អាយុ ៦ឆ្នាំ កូននេះត្រូវចូលរៀននឹងគេ ។ តើកូននេះរៀនចប់ចុងភូមិសិក្សាដែរ រឺទេ ? ។ ឪពុកម្ដាយក្ររកអ្វីមិនបាន និងមិនមានប្រាក់កាសទិញសំលៀកបំពាក់សមរម្យទិញសំភារៈសិក្សាអោយកូន ។ បន្ថែមលើនេះ កូនខ្លួនឯងផ្ទាល់មិនមានកំលាំងមាំមួន កំលាំងបញ្ញាក៏ទន់ខ្សោយ ។ នៅទីបំផុត សិស្សនេះត្រូវបោះបង់ការសិក្សាកណ្ដាលផ្លូវ ។ ពីរ រឺបីឆ្នាំក្រោយមក សិស្សនេះភ្លេចអក្សរអស់ ។ សិស្សនេះក្លាយទៅជាអនក្ខជនរឺត្រូវទៅដោយអវិជ្ជា ។ សិស្សនេះទៅជាពលរដ្ឋម្នាក់ល្ងង់ខ្លៅ ។ លុះគ្រប់អាយុគេគួស្រករ គេក៏រៀបអាពាហ៏ពិពាហ៏ជាមួយនារីម្នាក់មានជីវភាពប្រហាក់ប្រហែលគ្នា ។ នារីនេះមុខជានឹងបង្កើតកូនតទៅទៀត ។ នេះគឺជាការវិលត្រលប់មកភាពដើមវិញ ។ តើចាត់ទុកបុរសនេះ និងនារីនេះជាធនធានមនុស្សបាន រឺទេ ? សូមពិចារណា ?

ក្រៅពីកត្តាសុខភាព និងចំនីអាហារ គេសង្កេតឃើញមានកត្តាមួយទៀត គឺកង្វះបរិស្ថានបរិសុទ្ធ និងអនាម័យដែលជាមូលហេតុធ្វើអោយអត្រាជំងឺ និងអត្រាស្លាប់របស់កុមារពីអាយុ ៥ឆ្នាំ បានកើនឡើងយ៉ាងខ្ពស់ ។ ម្យ៉ាងទៀតបរិស្ថានសេដ្ឋកិច្ច និងសង្គម ក៏ជាឧបសគ្គមួយដ៏ធំរាំងអភិវឌ្ឍន៍ធនធានមនុស្សដែរ ។ យើងសង្កេតឃើញថា សព្វថ្ងៃនេះកំនើនប្រជាពលរដ្ឋកាន់តែខ្ពស់ ។ ដី ស្រែ ចំការ កាន់តែរឹលជីជាតិ ។ អាកាសធាតុ និងទឹកភ្លៀងមិនអនុគ្រោះដោយព្រៃឈើត្រូវហិនហោច ។ ភាពរាំងស្ងួត និងទឹកជំនន់ បានបំផ្លាញដំនាំកសិករ រាប់ពាន់ហិចតា ធ្វើអោយប្រជាពលរដ្ឋអត់

ស្បៀង អត់អ្វីផ្គត់ផ្គង់គ្រួសារអោយបានសមរម្យ ។ ពេលខ្លួនឯងឈឺ និងកូនឈឺត្រូវតែរកខ្ចីបុលគេ ។

រាជរដ្ឋាភិបាលនៅក្រ មិនអាចផ្ដល់ថវិកាគ្រប់គ្រាន់ដល់វិស័យកសាងធនធានមនុស្ស ព្រោះវិស័យដទៃទៀតត្រូវការកសាងជាបន្ទាន់ដែរ ។ ជំនួយឥតចំនង និងមានបំនងនៃប្រទេសអ្នកមាន មិនអាចគ្រប់គ្រាន់តាមតំរូវការនៃប្រទេសបានឡើយ ។

កត្តាមួយទៀតដែលសង្កេតឃើញថា អាចទាញថយក្រោយនៃការកសាងមុនស្ស គឺភាពអត់ការងារធ្វើ ។ ប្រជាពលរដ្ឋ ខិតខំរកទ្រព្យ ហើយអោយកូនមករៀនមានបំនងតែមួយ គឺអោយកូនមានឋានៈលើសខ្លួន ចង់អោយកូនមានបាន កុំអោយពិបាកដូចខ្លួន ។ នេះជាការពិតនៃចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរយើង ។ ចិត្តគំនិតនេះ វាដិតដាមមកដល់ទល់សព្វថ្ងៃ ។ ការងារពលកម្មដោយកំលាំងកាយមិនសូវចូលចិត្តបំពេញ ។ ប៉ុន្តែបច្ចុប្បន្នកាលនេះ ដោយស្ថានភាពស្រុកទេសលំបាក ការងារអ្វីក៏ធ្វើដែរកុំអោយតែត្រលប់ទៅស្រែ - ចំការវិញ ។ តែជាអកុសលសម័យនេះការងារមិនមាន រកមិនបាន ។ ប្រសិនបើមានវិញការងារនោះទាមទារចំនេះដឹងខ្ពស់ និងចេះភាសាបរទេសថែមទៀត ។

នៅស្រុក ខេត្តខ្លះដែលដីនៅមានដីជាតិល្អនៅឡើយ ឪពុកម្ដាយខ្លះអោយកូនមករៀនបានត្រឹមតែចប់បឋមភូមិ រឺមិនចប់ផង ដោយគេយល់ថា រៀនតទៅទៀតធ្វើអ្វី គង់តែត្រលប់មកធ្វើដីវិញដដែល ។ គំនោលនេះ មិនចាត់ទុកថាខុសទេ ព្រោះគេមិនទាន់យល់អោយបានស៊ីជំរៅនូវតំលៃនៃវិជ្ជា ។ គេគិតផ្នែកសំភារៈខ្លាំងជាង ។

កសិកម្មអន់ថយ ឧស្សាហកម្មមិនរីកចំរើនធ្វើអោយយុវជនកកស្ទះនៅទីក្រុង ទៅមុខមិនរួច ទៅក្រោយមិនរួច ។

ដូចនេះ ជាការសន្និដ្ឋាន អភិវឌ្ឍន៍ធនធានមនុស្សអោយបានជាកំលាំងប្រជាជាតិមានគ្រប់គុណសម្បត្តិ ត្រូវការការអប់រំ ការបណ្ដុះបណ្ដាលពិតមែនហើយ ព្រោះវាជាល័ក្ខខ័ណ្ឌមួយចាំបាច់នៃការកសាងមនុស្ស ។ ប៉ុន្តែការអប់រំនឹងប្រព្រឹត្តទៅបានប្រសិទ្ធភាពអាស្រ័យដោយកត្តា រឺដោយចលករជាច្រើន ។ ភាពក្រខ្សត់ដូចសព្វថ្ងៃ មិនអាចសង្ឃឹមថាប្រជាពលរដ្ឋបានរៀនសូត្រគ្រប់គ្នាមួយរយភាគរយនោះឡើយ ។

កង្វះវរជន (élite) ក្នុងការដឹកនាំវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយជាបញ្ហាចោទដ៏ក្ដៅគគុកនាបច្ចុប្បន្នកាលនេះ ។ រីឯពលរដ្ឋមានចំនេះដឹងទូទៅ និងបច្ចេកទេសថ្នាក់កណ្ដាលក្រសួងអប់រំ មិនទាន់មានលទ្ធភាពអប់រំអោយស្មើកំរិតអន្តរជាតិបាននៅឡើយទេ ។ ដូចនេះ ការកសាងធនធានមនុស្សទាមទារពេលវេលាដ៏យូរ និងទាមទារការរីកចំរើនសមស្របនៃសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ។

# សេពគប់មនុស្សបែបណា នៅជាបែបនោះ

# គោលបំណងនៃការបង្រៀន ប្រវត្តិ និង ភូមិវិទ្យានៃប្រទេសកម្ពុជា

ការសិក្សា ភូមិវិទ្យា និងប្រវត្តិវិទ្យា មានគោលបំនងអោយសិស្សយល់ដឹងពីអតីតកាលរបស់ខ្លួន ដែលគេភ្ជាប់ ភ្ជាមកទល់បច្ចុប្បន្នកាលនេះ ។ ការយល់ដឹងពីបច្ចុប្បន្នកាលបានច្បាស់លាស់ ទើបមានគំនិតកសាងអនាគតខ្លួន និងប្រទេសជាតិខ្លួន ។ រីឯ ភូមិវិទ្យាប្រាប់ទីតាំង រីដែនដីនៃប្រទេសកម្ពុជាក្នុងចំនោមប្រទេសជិតខាង និងប្រទេសទាំងឡាយទូទាំងពិភព លោក ។ តាមរយៈមេរៀននេះ សិស្សស្គាល់ប្រទេសខ្លួនពិតប្រាកដចាប់ពីភូមិ ឃុំ ស្រុក ខេត្ត រហូតដល់ប្រទេសទាំងមូល និងបានយល់ពីសកម្មភាពសេដ្ឋកិច្ច នយោបាយ និងបានយល់ដឹងពីសកម្មភាពសេដ្ឋកិច្ច នយោបាយ និងប្រជាពលរដ្ឋ ។ល ។

រីឯប្រវត្តិវិទ្យាវិញ បានប្រាប់ពីអតីតកាល ពូជអំបូររបស់ខ្លួន និងស្ថានភាពស្រុកទេសខាងផ្នែកគ្រប់គ្រងប្រទេស ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច - វប្បធម៌ ជាលំដាប់លំដោយចាប់តាំងពីកំនកំនើតប្រទេសរហូតមកដល់បច្ចុប្បន្ន ។ ដោយការសិក្សា សិស្សមានទឹកចិត្តស្រលាញ់ជាតិមាតុភូមិ ចូលរួមការពារសម្បត្តិធម្មជាតិ វប្បធម៌ និង បូរណភាពទឹកដី ។

ជាការសន្និដ្ឋាន ភូមិវិទ្យាកំនត់ដែនដី ( Espace ) ។ រីឯប្រវត្តិវិទ្យារាយរ៉ាប់ប្រាប់អតីតកាល ( passé ) ដ៏យូរលង់ណាស់មកហើយ ហើយបង្កើតបានជាសហគមន៍មួយមានវប្បធម៌ អរិយធម៌ប្លែកៗ ពីជនជាតិដទៃ ។

# សំភារឧបទេសសំរាប់បង្រៀនភូមិវិទ្យា

*** * ***

ប្រទេសកម្ពុជានៅមានកង្វះខាតសំភារឧបទេសជាច្រើនសំរាប់ការបង្រៀនគ្រប់មុខវិជ្ជា ។

តាមធម្មតាការបង្រៀនមុខវិជ្ជានីមួយៗ ទាមទារសំភារឧបទេសសមស្រប ទើបការពន្យល់មេរៀនមានកិរិតខ្ពស់ល្អ ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ លោកគ្រូ អ្នកគ្រូអាចផលិតសំភារៈខ្លះៗ បានដោយគ្រាន់តែចំនាយកំលាំងកាយ និងកំលាំងចិត្តប៉ុននោះ ដូចជាការគូរផែនទីសាលារៀនរបស់ខ្លួន ថ្នាក់រៀនរបស់ខ្លួន រួចឈានទៅគូរ ភូមិ ឃុំ ស្រុក ខេត្តរបស់ខ្លួន រហូតដល់ប្រទេសទាំងមូល ។ ចំពោះសំភារៈដទៃទៀតសំរាប់មេរៀនវិទ្យាសាស្ត្រអនុវត្ត ក៏លោកគ្រូ អ្នកគ្រូអាចផលិតបានខ្លះដែរ ។

ដើម្បីជាជំនួយចំពោះលោកគ្រូ អ្នកគ្រូក្នុងការផលិតផែនទី យើងខ្ញុំណែនាំអោយចេះគូរប្លង់ទៅតាមមាត្រដ្ឋាន ( échelle ) ។ ខ្ញុំមិនហ៊ានថា គ្រូយើងមិនចេះធ្វើប្លង់នោះទេ ព្រោះគ្រូយើងបានរៀនសូត្រខ្លះមកហើយ ។ ខ្ញុំគ្រាន់តែណែនាំបន្ថែម រំលឹកឡើងវិញតែប៉ុននោះ ។ ឧទាហរណ៍ ថាលោកនាយកសាលារៀនម្នាក់ព្រមទាំងលោកគ្រូ អ្នកគ្រូនៅ

សាលាមួយចង់បានផែនទីមួយទុកជាសំភារៈបង្រៀន រឺត្រូវការគូរផែនទីសាលារៀន ដើម្បីទុកជាប្លង់សំរាប់បំរុងដឹកសាងអគារទៅថ្ងៃក្រោយ ( Plan de masse ) ។ មុនដំបូងក្រុមបុគ្គលិកសិក្សាចាប់វាស់ទីធ្លាសាលារៀនដែលមានជាឧទាហរណ៍ បណ្តោយ ៣០០ម. ទទឹង ១៨០ម. ។ តើគាត់គូរទីធ្លានេះយ៉ាងដូចម្តេច ? គូរជាផ្ទៃបួនជ្រុងទ្រវែង ហើយសរសេរទទឹងបណ្តោយតាមប្រវែងដែលវាស់បានមក រឺទេ ? ទង្វើនេះបាន រឺទេ ? ឆ្លើយថា បាន តែផែនទីនេះមិនមានខ្នាតរង្វាស់ រឺមាត្រដ្ឋានឡើយ ។

ឧទាហរណ៍មួយទៀតថា លោកគ្រូ អ្នកគ្រូចង់ត្រូវការគូរប្លង់ ឃុំ រឺ ស្រុករបស់ខ្លួន ហើយដាក់ទីតាំងសាលានៅក្នុងស្រុកនោះ ដើម្បីទុកជាសំភារសំរាប់បង្រៀនភូមិវិទ្យា ។ តើគេត្រូវធ្វើដូចម្តេច ?

ឥលូវនេះ យើងនាំគ្នាគូរប្លង់ម៉ាស់សាលារៀនដែលមាន ៣០០ម. × ១៨០ម. លើក្រដាសទំហំ $A_4$ ( ក្រដាសបោះពុម្ពទស្សនាវដ្តីនេះ ) រឺលើក្រដាសធំជាងនេះ ។ ( កិច្ចការដែលចេញពីការដាក់ស្តែងទៅរកតំណាង រឺតាង ( de connu à la représentation ) នេះជាទង្វើមួយស្របទឹងគោលដៅនៃការបង្រៀនភូមិវិទ្យា ) ខ្ញុំកំនត់ជូនមាត្រដ្ឋាន 1/1200 គឺ ១ស.ម. ស្មើ ១២ម៉ែ. ។ ដូចនេះ នៅលើក្រដាស $A_4$ បណ្តោយទីធ្លាត្រូវ ២៥ស.ម. ទទឹង ១៥ស.ម. ។ អគារសិក្សាមានហើយ និងសំនង់ទៅថ្ងៃមុខត្រូវមានមាត្រដ្ឋានដូចគ្នា ។ នេះជាឧទាហរណ៍ប៉ុននោះ ។ ប្រសិនបើគូរនៅលើក្រដាសធំ មាត្រដ្ឋានត្រូវតែប្តូរ ។

នៅលើផែនទីធំ អ្នកគូរផែនទីច្រើនកំនត់យក ១ស.ម. ( មួយធ្នឹង ) ស្មើនិង ១ គ.ម. រឺ ៥ គ.ម. តាមផ្ទៃក្រដាសធំ រឺតូច ។ ផែនទីប្រទេសកម្ពុជាមានមាត្រដ្ឋាន 1/500 000 ។ គឺ ១ ស.ម. = ៥ គ.ម ។

ចំពោះការសិក្សាអំពីទិស សិស្សខ្លះស្គាល់ទិសទាំងប្រាំបី (៨) ។ គេអាចចង្អុល និងអោយឈ្មោះបាន ។ ប៉ុន្តែសិស្សខ្លះទៀតអាចរាប់បានតែទិសបួន (4) អនុទិសបួនទៀតគេចង្អុលមិនបានចំ ថែមទាំងមិនចេះអោយឈ្មោះទៀតផង ។

យើងបានសួរសិស្សជាច្រើននាក់ ។ យើងជួបប្រទះច្រើន តែអ្នកមិនដឹងថា ខេត្តស្ទឹងត្រែង បន្ទាយមានជ័យស្ថិតនៅទិសណា ។ នៅលើផែនទី គេមិនដឹងថា ខាងណាខាងជើង ខាងត្បូង ខាងកើត ខាងលិចផង ។

ចំពោះបញ្ហានេះ តើលោកគ្រូ អ្នកគ្រូគិតយ៉ាងណា ? ទុកអោយនៅល្ងង់មួយជីវិតទៅរឺ ? សូមអោយសិស្សទន្ទេញចាំរត់មាត់នូវទិសទាំងប្រាំបី (៨) ហើយអោយចេះចង្អុលទិសនៅលើផែនទី ។

ដើម្បីជាជំនួយចំពោះលោកគ្រូ អ្នកគ្រូ ខ្ញុំសូមជូនវិធីរកទិសតាំងណាមួយនៅលើផែនទី ។

**1. គូរក្បាច់ផ្កាចន្ទន៍ រឺ ដកចន្ទន៍នៅលើក្រដាសរឹង ។**

ចោះប្រហោងមូលតូចល្មមនៅចំកណ្តាល ។

**2. ដាក់ផ្កាចន្ទន៍នៅលើផែនទី ប្រហោងមូលដាក់ចំទីតាំងឈរជើង ។ ទិសខាងជើង « ឧត្តរ » ឡើងលើ ។**

ឧទាហរណ៍ : សិស្សខេត្តកំពង់ចាមចង់ដឹងថា ខេត្តស្វាយរៀង រឺខេត្តបាត់ដំបងនៅទិសណា ?

( រូបផ្កាចន្ទន៍នៅក្របខាងក្នុង ខាងក្រោយ ។ សូមធ្វើអោយបានធំលើក្រដាសក្រាស ។ )

# ស្វែងយល់លើមេរៀនប្រវត្តិវិទ្យា

ក្នុងគោលបំណងលើកកំពស់ចំណេះដឹងផ្នែកប្រវត្តិវិទ្យា ខ្ញុំសូមលើកមកបំភ្លឺបន្ថែមអំពី :

1. ពុទ្ធសករាជ គ្រិស្តសករាជ មហាសករាជ ចុល្លសករាជ
2. សម័យបុរេប្រវត្តិសាស្ត្រ និង សម័យប្រវត្តិសាស្ត្រ

I. សព្វថ្ងៃនេះ ពិភពលោកនិយមប្រើគ្រិស្តសករាជក្នុងសំណេរប្រវត្តិសាស្ត្រ លិខិតស្នាម និងក្នុងការនិយាយស្តីជាដើម ។ គេកំណត់យកឆ្នាំកំណើតព្រះយេស៊ូគ្រិស្តជាគោលនៃការរាប់ឆ្នាំ ។ គេរាប់ទៅមុខ ថយក្រោយចំពោះព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលមានមុន រឺក្រោយកំណើតព្រះយេស៊ូគ្រិស្ត ។ ឧទាហរណ៍ : ព្រះពុទ្ធទ្រង់ប្រសូតក្នុងសតវត្សទី 6 មុនគ្រិស្តសករាជ ។ សូក្រាត ទស្សនវិទូក្រិក កើតក្នុងឆ្នាំ 470 មុនគ.ស. ។ ប្រាសាទអង្គរវត្តបានកសាងក្នុងគ.ស. 1112 ( ក្រោយគ.ស. ) ។

យើងបានដឹងថា ក្នុងឆ្នាំ 1995 នេះ ពុទ្ធសករាជកន្លងទៅបាន 2539 ឆ្នាំហើយ ។ ដូចនេះ គេសួរថា ព្រះពុទ្ធបរិនិព្វានបានប៉ុន្មានឆ្នាំទើបព្រះយេស៊ូគ្រិស្តប្រសូត្រ ។ ប្រជាពលរដ្ឋខ្មែរធ្វើបុណ្យពាក់កណ្តាលពុទ្ធសាសនាទៅក្នុង ព.ស. 2500 តើត្រូវនឹងគ.ស.ប៉ុន្មាន ? ។ ប្រាសាទអង្គរវត្តសាងក្នុងគ.ស.ប៉ុន្មាន ? ត្រូវនឹងព.ស.ប៉ុន្មាន ។

បន្ថែមទៅលើសករាជទាំងពីរខាងលើ នៅប្រទេសកម្ពុជាយើងគេបានប្រើក្នុងព្រះរាជពង្សាវតាសករាជពីរទៀតគឺ មហាសករាជ និងចុល្លសករាជដែលមានកំណើតចាប់តាំងពី ៖

មហាសករាជ គឺព្រះបាទសម្តេចព្រះអរិដ្ឋពលពាហនា ( ព្រះកេតុមាលា ) បានតាំងមហាសករាជ 1ក្នុងកាលពុទ្ធសករាជ 621 ។

ចុល្លសករាជ គឺព្រះបាទសម្តេចព្រះបទុមសុរិយវង្ស បានតាំងចុល្លសករាជ 1 ក្នុងកាលពុទ្ធសករាជ 1183 ។

## កំណើតព្រះយេស៊ូគ្រិស្ត




* 100 ឆ្នាំមុន គ.ស. រឺ សតវត្សទី 1 មុនគ.ស

* 100 ឆ្នាំក្រោយគ.ស. រឺ សតវត្សទី ១ នៃគ.ស

* គេច្រើនសរសេរគំនូស (-) សំគាល់ឆ្នាំមុន គ.ស. ឧ. -5000 ឆ្នាំ គេអានថា 5000 ឆ្នាំមុន គ.ស. ។

* រយៈកាល 1000 ឆ្នាំហៅថា សហស្សវត្សទី 1..

## II. សម័យបុរេ រឺ មុនប្រវត្តិសាស្ត្រ និង សម័យប្រវត្តិសាស្ត្រ

### 1. សម័យបុរេប្រវត្តិសាស្ត្រ

ជាសម័យដ៏យូរលង់អង្វែងមុនប្រវត្តិសាស្ត្រ ។ គេគិតចាប់ពីមនុស្សចេះដើរដោយជើងទាំងពីរខាងក្រោយ ហើយចាប់ប្រើជើងមុខជាដៃសំរាប់កាន់ឧបករណ៍ផ្សេងៗ ។ គឺប្រមាណ 3 លានឆ្នាំមកហើយ ហើយវិវត្តមករហូតដល់ 3 200 ឆ្នាំមុនគ.ស. ដែលជាឆ្នាំកំនើតអក្សរនៅបូព៌ាប្រទេស ។

សម័យបុរេប្រវត្តិចែកចេញជាបី (3) យុគ គឺ :

១. យុគប្រើប្រដាប់ប្រដាធ្វើអំពីថ្មដុល ( La Paléolithique ) ចាប់ពីមានមនុស្សរហូតដល់ប្រមាណឆ្នាំ 6000 មុនគ.ស. ។

២. យុគប្រើប្រដាប់ប្រដាធ្វើអំពីថ្មរំលីង ( La Néolithique ) មានអាយុកាលប្រមាណ 6000 ឆ្នាំមុនគ.ស. ។

៣. យុគប្រើប្រដាប់ប្រដាធ្វើអំពីលោហធាតុ មានអាយុកាលប្រមាណ 2000 ឆ្នាំមុនគ.ស. ។

បំនែងចែកបុរេប្រវត្តិជាបីយុគនេះ ពាក់ព័ន្ធតែទៅលើប្រវត្តិសាស្ត្រសាកលលោក ។ ឥលូវនេះ យើងងាកមកសិក្សាពីសម័យបុរេប្រវត្តិនៃប្រទេសកម្ពុជាយើងម្តង ។

តាមការរុករកនៃបុរាណវត្ថុវិទូនៅស្ថានីយ៍ដែលមាននៅប្រទេសកម្ពុជា គេរកឃើញតែស្ថានីយ៍នាយុគថ្មរំលីង រឺ សំលៀង ( La Néolithique ) និងយុគលោហៈដែលមានអាយុកាលចាស់ជាងគេ 4 290 ឆ្នាំ មុនគ.ស. និងក្មេងជាងគេ 180 ឆ្នាំមុនគ.ស. - 800 ឆ្នាំក្រោយគ.ស. ។

- ស្ថានីយ៍ល្អាងស្ពាន នៅអណ្តើកហែប ខេត្តបាត់ដំបង (4.290 មុនគ.ស. )
- ស្ថានីយ៍ក្បាលរមាសនៅខេត្តកំពត ( 3.420 ឆ្នាំមុនគ.ស. )

ក្រៅពីនេះ មានស្ថានីយ៍សំរោងសែន អន្លង់ផ្តៅ និងម្លូព្រៃ ដែលគេកំនត់អត្ថិភាពមិនទាន់បាន ។ រីឯស្ថានីយ៍មេមត់ មានអាយុកាលពី 1500 ដល់ 500 ឆ្នាំមុនគ.ស. ។ ស្ថានីយ៍ចំការលើ និងដុប មានអាយុកាលពីឆ្នាំ 180 មុនគ.ស. ដល់ឆ្នាំ 800 នៃគ.ស. ។

ដូចនេះ ផ្អែកលើឯកសារខាងលើ យើងអាចសន្និដ្ឋានថា ប្រទេសកម្ពុជាមានកុលសម្ព័ន្ធរស់នៅចុងយុគថ្មរំលីង និងយុគលោហៈ ។ រីឯយុគថ្មដុលប្រហែលជាមិនមានឡើយ ។

ចំពោះជីវភាពរស់នៅរបស់ខ្មែរក្នុងសម័យមុនគ.ស. ។

សូមលោកគ្រូ អ្នកគ្រូស្វែងយល់បន្ថែមទៀត ព្រោះឯកសារមានគ្រប់គ្រាន់ហើយ និយាយពី :

- ឧបករណ៍សំរាប់បង្កបង្កើនផល
- របៀបរស់នៅ
- ទំនៀមទំលាប់ និងជំនឿ
- លំនៅឋាន

- របៀបគ្រប់គ្រង

## 2. សម័យប្រវត្តិសាស្ត្រ :

គឺជាសម័យចាប់រាប់ពី 3.200 ឆ្នាំមុនកំណើតព្រះយេស៊ូគ្រិស្ត ។ មកទល់បច្ចុប្បន្នកាលនេះ ( គ.ស. 1995 ) សម័យប្រវត្តិសាស្ត្រសាកលមានថេរវេលា ( អាយុ ) 5195 ឆ្នាំហើយ ។

សូមជំរាបថា សម័យប្រវត្តិសាស្ត្រមានសភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។

សម័យប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់រាប់ពីសតវត្សទី 1 នៃគ.ស. ពោលគឺទើបបាន 1995 ឆ្នាំប៉ុណ្ណោះ ។

សរុបមក ខ្មែររស់នៅជាកុលសម្ព័ន្ធមានមេកន្ទ្រាញដូចកុលសម្ព័ន្ធដទៃទៀតក្នុងសម័យបុរេប្រវត្តិអស់រយៈកាលជាង 4000 ឆ្នាំមុនគ.ស. ( ស្ពានទីយ៍ល្ពាងស្ពាន ) ហើយរស់នៅក្នុងសម័យប្រវត្តិសាស្ត្រជិតបានពីរសហស្សវត្ស ( 2000 ឆ្នាំ ) ហើយ ( នៅ 5 ឆ្នាំទៀត ) ។

តាមឯកសារមេរៀនប្រវត្តិសាស្ត្របារាំង បំនែងចែកយុគបន្តពីបុរេប្រវត្តិមានដូចគំនូសខាងក្រោម ។

### កំណើតព្រះយេស៊ូគ្រិស្ត





# រៀនសង្កេត និង ពិចារណា

កុមារា កុមារី ទាំងប្រាំមួយនាក់នេះ ( ថតកាលពីឆ្នាំ ១៩២១ ដោយទេសចរណ៍បារាំងម្នាក់ ) កំពុងអង្គុយលេង និងលក់នំ និងផ្លែឈើផង នៅលើកាំជណ្តើរថ្មឡើងចូលទៅប្រាសាទ អង្គរវត្ត ។

**សំនួរ :**

- កុមារា កុមារីនេះអាយុប្រហែលប៉ុន្មាន ? ឥឡូវនេះ គេមានអាយុប៉ុន្មានហើយ ប្រសិនបើគេនៅរស់មកទល់សព្វថ្ងៃនេះ ?
- សូមប្រៀបធៀបជីវភាពរស់នៅរបស់ក្មេងនៅជំនាន់នោះ នឹងនៅជំនាន់ក្មេងនាបច្ចុប្បន្នកាលនេះ ។
- រូបគោ និង នាគ តើសង់ពីឆ្នាំណា ?

# វិញ្ញាសាប្រលងជ្រើសរើសអធិការបឋមសិក្សាជំនាន់ទី ២
## ( សម័យប្រលងថ្ងៃទី ១០-១០-៩៥)

## វិញ្ញាសាទី ១ :

កំនត់សំយោគ ( រយៈពេល : ៣ ម៉ោង )

### សំនួរ

ផ្អែកតាមអត្ថបទជូនភ្ជាប់នេះ ចូរឆ្លើយនូវសំនួរដូចខាងក្រោម ៖

១- តើក្នុងអត្ថបទនេះ អ្នកនិពន្ធ ចង់និយាយអំពីអ្វីខ្លះ ? ចូរសង្ខេបគំនិតសំខាន់ៗ ទាំងនោះ អោយបាន ៥ឃ្លា ។ « ១ ពិន្ទុ »

២- តើអ្នកយល់ដូចម្តេចអំពីគោលការណ៍សេរីភាពក្នុងការសិក្សា និង គោលការណ៍សមភាពក្នុងការអប់រំ ? « ២ ពិន្ទុ »

៣- តើអ្វីខ្លះជាកត្តាសំខាន់ក្នុងការកំនត់គុណភាពអប់រំ ? « ២ ពិន្ទុ »

៤- តើត្រូវធ្វើដូចម្តេច ដើម្បីបង្កើនអត្រាកុមារចូលរៀន និងកាត់បន្ថយអត្រាកុមាររៀនត្រួតថ្នាក់ និងកុមារបោះបង់ចោលការសិក្សា ? « ២ ពិន្ទុ »

៥- ក្នុងឋានៈជាអធិការបឋមសិក្សា តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីអនុវត្តពលកម្មអប់រំ និងទំនើបកម្មអប់រំនៅបឋមសិក្សា ? « ៣ ពិន្ទុ »

« ... បច្ចុប្បន្ននេះការអប់រំស្ថិតនៅក្នុងវិបត្តិដ៏គ្រោះថ្នាក់មួយ ។ មនុស្សពេញវ័យជិតមួយពាន់លាន ពោលគឺ 1 / 5 នៃមនុស្សជាតិលើសកលលោកជាអនក្ខជន កុមារប្រមាណមួយរយលាននាក់ គ្មានភ័ព្វវាសនាបានរៀនសូត្រ ។ ចំពោះមុខនេះការមិនរីកចំរើនទៅមុខខាងសេដ្ឋកិច្ច និងវិបត្តិខាងហិរញ្ញវត្ថុ បានបង្ខំអោយរដ្ឋាភិបាល នៃប្រទេសជាច្រើនកាត់បន្ថយចំនាយទៅលើការងារសង្គមគិតទាំងការងារអប់រំផង ។ ប្រការនេះធ្វើអោយមានការធ្លាក់ចុះយ៉ាងឆាប់រហ័ស នូវអត្រាកុមារចូលរៀន និងកុមារបោះបង់ចោលថ្នាក់រៀន ចាប់ពីទសវត្សឆ្នាំ ៧០ និងដើមទសវត្សឆ្នាំ ៨០ ។

សន្និសីទ ពិភពលោក ឆ្នាំ ១៩៩០ នៅប្រទេសថៃ បានបង្ហាញនូវគំនិតផ្តួចផ្តើម ជាប្រវត្តិសាស្ត្រដែលជាទស្សនៈថ្មីមួយដ៏ត្រឹមត្រូវ ស្តីពីការអប់រំសំរាប់ទាំងអស់គ្នា " **Education pour tous / Education for all** " ។ សន្និសីទនេះត្រូវបានឧបត្ថម្ភ និងគាំទ្រដោយកម្មវិធីរបស់អង្គការសហប្រជាជាតិ ដើម្បីអភិវឌ្ឍន៍វិទ្យាសាស្ត្រ និងវប្បធម៌

ដោយអង្គការមូលនិធិកុមារ នៃអង្គការសហប្រជាជាតិ និងដោយធនធានភិភពលោក ។ គោលបំណងនៃសន្និសីទ គឺប្រមូលផ្តុំធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីជួយឧបត្ថម្ភដល់កុមារ និងមនុស្សពេញវ័យអោយអាចទទួលបាននូវចំនេះដឹង និងមុខជំនាញសំរាប់កែលំអជីវភាពរស់នៅ និងសហគមន៍របស់គេ ។

ដើម្បីប្រែក្លាយគោលបំណងនេះអោយទៅជាការជាក់ស្តែង គេមានជំនឿថា ទាល់តែមានឧបត្ថម្ភគាំទ្រ និងឯកភាពពីសហគមន៍អន្តរជាតិលើសកលលោកទាំងមូល ដែលបច្ចុប្បន្ននេះកំពុងខិតខំបង្កើតសក្តានុពលភាពខាងកិច្ចសហប្រតិបត្តិការអន្តរជាតិឆ្ពោះទៅរកទស្សនៈថ្មីមួយដ៏ទូលំទូលាយ គឺចង់កសាងពិភពលោកមួយប្រកបដោយសន្តិភាព និងស្ថេរភាព ។ ប្រការនេះត្តូបផ្សំនឹងកិច្ចអភិវឌ្ឍន៍ខាងវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា គឺជាលក្ខណៈអំណោយផលសំរាប់អនុវត្តអប់រំជាមូលដ្ឋានការអប់រំសំរាប់ទាំងអស់គ្នាប្រកបដោយយុត្តិធម៌ និងសមធម៌ ។

បទពិសោធន៍អឺរ៉ុប នៅអាមេរិកខាងជើង ហើយថ្មីៗនេះនៅប្រទេសជប៉ុន ប្រទេសសិង្ហបុរី និងសាធារណរដ្ឋកូរ៉េ បានអះអាងថា ការអប់រំជាមូលដ្ឋានសំរាប់មនុស្សគ្រប់រូប ត្រូវតែបានសំរេច ហើយការងារនេះ គឺជាចំនែកមួយយ៉ាងសំខាន់សំរាប់អភិវឌ្ឍន៍ប្រទេសជាតិ ។

ពិនិត្យមើលស្ថានភាពបច្ចុប្បន្ននៅកម្ពុជា សង្គ្រាមជាងពីទសវត្សចុងក្រោយកន្លងទៅនេះ បានបង្កឡើងនូវវិនាសកម្ម និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងគ្រប់វិស័យ និងគ្រប់ផ្នែក ។ ធនធានមនុស្សត្រូវបានបំផ្លិចបំផ្លាញ ជនពិការកុមារកំព្រាស្រ្តីមេម៉ាយ និងក្រុមជនមានការលំបាកត្រូវបានបន្សល់ទុក ប្រែក្លាយកម្ពុជាអោយទៅជាប្រទេសមួយក្រីក្របំផុត បើប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់ និងប្រទេសលើសកលលោក ។

ចាប់ពីឆ្នាំ ១៩៧៩ ទោះបីមានការខិតខំប្រឹងប្រែងដើម្បីស្តារ និងកសាងទឹកដីឡើងវិញយ៉ាងណាក៏ដោយ ក៏សូចនាករសង្គម នៅមានកំរិតទាប ផលិតផលក្នុងស្រុកសរុបសំរាប់ប្រជាពលរដ្ឋម្នាក់ៗ បានត្រឹមតែ 170ដុល្លាប៉ុននោះ ។ និយាយរួមស្ថានភាពនៃធនធានមនុស្សនៅកម្ពុជាសព្វថ្ងៃ គឺមានចរិតលក្ខណៈមនុស្សមានសមត្ថភាព និងមានគុណសម្បត្តិសំរាប់ចូលអភិវឌ្ឍន៍សង្គម - សេដ្ឋកិច្ចអោយបានសមស្របទៅនឹងតំរូវការជាបន្ទាន់នៃសេដ្ឋកិច្ច ទីផ្សារក្នុងក្របខ័ណ្ឌនយោបាយសេរីនិយកម្ម និងឯកជននីយកម្ម ។

ស្ថិតនៅក្នុងបរិបទនេះ ជំពូក ៦ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា បានចែងពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិតសិក្សា ។ តួនាទីរបស់រដ្ឋត្រូវកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពក្នុងទូទាំងប្រទេស ។ គោលការណ៍សេរីភាពខាងសិក្សា និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីអោយពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ និងស្មើៗគ្នាក្នុងការកសាងជីវភាពត្រូវបានធានាក្នុងប្រព័ន្ធអប់រំ ។ រដ្ឋផ្តល់ការអប់រំផ្នែកបឋមសិក្សា និងមធ្យមសិក្សានៅតាមសាលារៀនសាធារណៈ សំរាប់ពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ហើយការអប់រំ ៩ឆ្នាំត្រូវក្លាយទៅជាកាតព្វកិច្ចសិក្សា សំរាប់ពលរដ្ឋទាំងអស់ ។

ផ្អែកលើច្បាប់រដ្ឋធម្មនុញ្ញជាមូលដ្ឋាននេះ ក្រសួងអប់រំ យុវជន និងកីឡា មានភារៈកិច្ចចាំបាច់ និងជាបន្ទាន់រៀបចំកែលំអ និងកែទំរង់ប្រព័ន្ធអប់រំដើម្បីលើកកំពង់ថែមទៀតនូវគុណភាពអប់រំក្នុងគ្រប់ផ្នែក និងគ្រប់ភូមិសិក្សាក្នុងទូទាំងប្រទេស ។ ក្នុងចំនោមកម្មវិធី និងសកម្មភាពអាទិភាពជាច្រើនដែលត្រូវធ្វើ ក្រសួងបានកំនត់ការងារ ៣ ជាយុទ្ធសាស្រ្ត គឺសកលកម្មអប់រំ ទំនើបកម្មអប់រំ និងកែលំអការងារគ្រប់គ្រងដោយចាប់ផ្តើមពីបឋមសិក្សា . . . »

## វិញ្ញាសាទី ២ : - ភាសាបារាំង Epreuve de français ( រយៈពេល ២ម៉ោង )

**LISEZ CE TEXTE :**

La croissance démographique au Cambodge, comme dans beaucoup d'autres pays en voie de développement, rend pressants les besoins en éducation, besoins qu'il est souvent difficile de satisfaire dans des conditions convenables. En effet, les budgets accordés au système éducatif ne permettent pas de répondre à toutes les demandes de la population scolarisée, et encore moins d'absorber l'ensemble de la population scolarisable.

Après la libération de Janvier 1979, dans les classes maternelles et primaires cambodgiennes, une des solutions adoptées pour scolariser fut l'augmentation des effectifs par classe, surtout dans les régions urbaines, bien que la moyenne par classe soit rarement intérieure à 50 élèves et dépasse souvent la centaine, Au Cambodge, aujourd'hui, ce sont ainsi développées les classes à grands groupes.

En dépit de ces difficultés, après l'élection générale de mai 1993, le Gouvernement Royal a voulu démocratiser, généraliser et promouvoir la qualité du système éducatif, notamment aux niveaux de l'enseignement primaire et maternel dans tout le pays.

L'enseignement primaire et maternel a une grande influence sur le développement mental et social de chaque enfant. Dans la plupart des établissements primaires et maternels, les auxiliaires pédagogiques sont rares et le matériel didactique est presque inexistant. Les besoins en matériels didactiques sont considérables à tous les niveaux primaires et maternels. De plus, programme et matériels ont besoin d'être revus et améliorés.

En Septembre 1994, le Gouvernement reconstitue le corps d'inspection primaire et maternelle. Le corps d'inspection a pour mission de moderniser le système éducatif et d'en améliorer la qualité par la formation des enseignements, le contrôle de l'enseignement, l'évaluation des acquisitions des élèves.

## QUESTIONS :

**I . De quoi parle-t-on dans ce texte ? (1/2 pt )**

**II . Répondez aux questions suivantes :**

a) D'après ce texte, qu'est-ce qu'on doit faire pour améliorer l'enseignement primaire et maternel ? ( 1pt )

b) Pourquoi aimeriez-vous être inspecteur de l'enseignement primaire ? ( 1 1/2 pt )

**III . Ecrivez le contraire des mots soulignés dans les phrases suivantes : (1 pt )**

a) Dans les régions **urbaines**, l'effectif des élèves par classe est **inférieur** à 50

b) Les matériels didactiques et les auxiliaires pédagogiques dans les écoles primaires et maternelles sont **rares**.

c) Une des solutions les plus commodes, dans les écoles primaires et maternelles est **l'augmentation** des effectifs.

**IV . Mettez les phrases suivantes à la forme passive. ( 2 pts )**

a) Le corps d'inspection améliorera le système éducatif.

b) Les ONG et les experts étrangers ont fourni des aides pour la construction des bases de matériels didactiques.

c) L'améliorationm du système éducatif absorbe l'ensemble de la population scolarisable.

d) A l'aide des matériels didactiques, l'enseignement de toutes les disciplines attirerait l'attention des enfants.

**V. Complétez les phrases suivantes par : QUI, QUE, DONT, Où. (1 pt)**

a) Il cherche une revue pédagogique . . . . il a mise sur l'étagère.

b) L'école . . . . . il parle est construite conformément aux normes pédagogiques.

c) La salle . . . . vous vous trouvez fait partie de cette école.

d) Cette école . . . . . . date de 1947, est à présent le Centre de Formation des instituteurs.

**VI. Répondez négativement aux questions suivantes. (1pt)**

a) Entendez-vous quelque chose là-dessous ?

b) Trouvez-vous quelqu'un dans le bureau ?

c) Allez-vous souvent à la bibliothèque le samedi après-midi ?

d) Avez-vous mis la revue pédagogique dans mon sac ?

**VII. Dans les phrases suivantes, mettre les verbes au temps composé correspondant. Mettre ensuite les phrases aux formes : négative, interrogative interro-négative ( sans employer << est-ce que >> ). ( 2 pts )**

a) Vous vous en souvenez.

b) nous nous y ferons.

## English Test

**I. Match a line in A with a line in B to make a question. ( 1 mark )**

| A | B |
|---|---|
| a) Where | languages do you speak ? |
| b) Who | is a cup of coffee and a sandwich ? |
| c) How much | do you usually sit next to ? |
| d) How many | do you go on holiday ? |

**II. Practice putting the prepositions ( With, of, to, at, in ) into these sentences. ( 1 mark)**

a) Can you help me . . . . . my homework ? Of course. Give it . . . . me.

b) Look . . . . . . . . this photo . . . . . . . my girlfriend. Isn't she beautiful ?

c) My father was born . . . . . . . . Phnom Penh . . . . . . . . 1936.

d) He studies . . . . . . . . . home . . . . . . . . . . his brother.

**III . Change these sentences into the passive voice. ( 1 mark )**

a) The house has been built.

b) He was killed.

c) A cat is eating a mouse.

d) They have been learning English.

**IV . Put these sentences into indirect speech. ( 1 mark )**

a) He said : << I cannot meet you here either to-day or tomorrow >>

b) He said : << I shall come here to take this book >>

c) They said : << We did it yesterday >>

d) She said : << His father died last year >>

**V . Make the following sentences plural. ( 1mark )**

a) The man is a thief

b) Put a knife on the table.

c) The man and his wife live in a good house.

d) I ask the dentist to pull out my tooth.

**VI . Practice putting the adverbs in the correct sentence . ( 1 mark )**

a) He sold the gold watch ( immediately ).

b) I had noticed her. ( frequently ).

c) He was escorted from the room ( quickly ).

d) John waited for me ( Seldom ).

**VII . Write number of the word in column B that has the same meaning as the word in column A. Put the number on the line provided. ( 1 mark )**

| A | B |
|---|---|
| ....... a) unwise | 1) unscathed |
| ....... b) unharmed | 2) illiterate |
| ....... c) unavoidable | 3) imprudent |
| ....... d) unable to read and write | 4) inevitable |

**VIII . Choose the correct answer. (1 mark )**

a) If water is heated to 100 degrees C ........ as steam.

A) it will boil and escape C) it boil and escape

B) it's boiling and escaping D) it would boil and escape

b) John finished .......... two of his published compositions before his tenth birthday.

A) written C) to write

B) write D) writing

**IX . Write a topic for 10 sentences telling about : << Why do you want to become a primary school inspector ? >> ( 2 marks )**

**វិញ្ញាសាទី ៣ :** វប្បធម៌ទូទៅ ( រយៈពេល ១៨០នាទី )

**ប្រធាន :**

គេតែងពោលថា : « ដើម្បីអភិវឌ្ឍន៍ជាតិ ចាំបាច់ ត្រូវតែអភិវឌ្ឍន៍វិស័យអប់រំជាបឋម » ។
ចូរអ្នកពន្យល់ស្រាយបំភ្លឺ ។

*

* *

# គុណសម្បត្តិគ្រូបង្រៀន

គ្រូបង្រៀន ទោះជាមានលំដាប់ថ្នាក់ខុសគ្នាយ៉ាងណាក៏ដោយចុះ ( ក ខ គ ឃ ) ក៏អ្នកស្រុក អ្នកភូមិ សិស្សានុសិស្សហៅថា លោកគ្រូ អ្នកគ្រូទាំងអស់ ។

- គ្រូ « គរុ ( បាលី ) គុរុ ( សំស្ក្រឹត ) » ជាអ្នកដែលមានចិត្តធ្ងន់ អ្នកដែលគេគួរគោរព ។
- បង្រៀន គឺញ៉ាំងអ្នកដទៃអោយរៀន បង្រៀនអោយចេះ អោយចំនេះដោយការបង្ហាត់បង្ហាញចំនេះគ្រប់បែបយ៉ាង . . . ។

បច្ចុប្បន្នកាលនេះ នៅបស្ចិមប្រទេស គេមានទំនោរយកពាក្យគ្រូបង្រៀន ( enseignant ) ទៅប្រើចំពោះគ្រូនៅសាកលវិទ្យាល័យ វិទ្យាល័យ អនុវិទ្យាល័យ និងបឋមសិក្សា ។ ដូចនេះ គួរយើងយល់ថា អ្នកបង្រៀន រឺគ្រូបង្រៀន ជាគោរម្យងារចំពោះមនុស្សដែលទទួលមុខងារបង្ហាត់បង្រៀនមនុស្សដទៃ ។

មុខងារគ្រូបង្រៀនជាមុខងារដ៏លំបាក ទាមទារគុណសម្បត្តិ ( qualités ) ខាង ៖

1. **រូបរាងកាយ**
2. **បញ្ញា**
3. **វិជ្ជាជីវៈ**
4. **ចរិយា**

ចំពោះគុណសម្បត្តិទាំងបួននេះ ខ្ញុំសូមលើកយកគុណសម្បត្តិទី 1 ទី3 និងទី 4 មកធ្វើអត្ថាធិប្បាយ ដើម្បីជាជំនួយស្មារតី និងដុសខាត់មនសិការការងាររបស់អ្នកបង្រៀន ។

សូមជំរាបថា គុណសម្បត្តិខាងចំនេះដឹង រឺបញ្ញា រឺ វប្បធម៌ គឺបានមកពីការរៀនសូត្ររបស់លោកគ្រូ អ្នកគ្រូ ចាប់តាំងពីចូលសាលាបឋមសិក្សា ។ ចំនេះដឹង រឺ ពុទ្ធិបានរីកធំធាត់បន្តិចម្តងៗ ទៅតាមដំនើរឈានឡើងនៃសិស្ស គឺពីបឋម

មធ្យមទៅឧត្តមសិក្សា ។ ពុទ្ធិចំបងទាំងពីរប្រភេទ គឺវិទ្យាសាស្ត្រពិត រឺធម្មជាតិ និងវិទ្យាសាស្ត្រសង្គម ដែលនិស្សិតបានក្រេបជញ្ជក់ក្នុងការសិក្សាបង្កើតបានជាការយល់ ការដឹង ដែលយើងហៅថា បញ្ញា ( Intelligence ) ។ បញ្ញានាំអោយចេះត្រិះរិះពិចារណា វិនិច្ឆ័យ និងមានគំនិតវែកញែក ដែលទុកជាគំលៃរបស់បុគ្គល ។ វិទ្យាសាស្ត្រពិតនាំអោយយើងយល់ដឹងពីធម្មជាតិ ។ រីឯវិទ្យាសាស្ត្រសង្គមនាំអោយយើងយល់ដឹងពីមនុស្ស និងសង្គមមនុស្ស ។

ក្រោយពីបានទទួលពុទ្ធិបានតិច រឺច្រើនទៅតាមកំលាំងរៀនសូត្ររបស់ខ្លួនហើយ និស្សិតថ្នាក់មធ្យម និងឧត្តមមួយចំនួនបានសុំធ្វើគ្រូបង្រៀន ដោយសុខចិត្តអោយក្រសួងអប់រំជ្រើសរើសតាមការប្រលងប្រជែងទៅតាមសមត្ថភាពរបស់ខ្លួន ។

កាលណាបានជាប់ហើយ គរុសិស្សត្រូវតែទទួលការបណ្តុះបណ្តាលគរុកោសល្យជាចាំបាច់ ដើម្បីអោយចេះផ្ទេរចំនេះដឹងរបស់ខ្លួនទៅដល់សិស្ស ( វិជ្ជាជីវៈសម្បត្តិ ) ។ បើមិនដូចនោះទេ គេមិនទាន់ចាត់ទុកជាគ្រូបង្រៀននៅឡើយទេ ។

ប្រសិទ្ធភាពនៃការបង្រៀនចំនុះមួយភាគធំទៅលើគ្រូមានសមត្ថភាពបរិបូរណ៍ផ្នែកចំនេះដឹងទូទៅ និងគរុកោសល្យ គឺចេះប្រើវិធីសាស្ត្រ និងល្បិចងាយៗក្នុងការបង្រៀន ។ ប៉ុន្តែសមត្ថភាពនេះមិនទាន់សព្វគ្រប់នៅឡើយទេ ។ ការបង្រៀនសិស្សទាមទារគុណសម្បត្តិមួយទៀត គឺចរិយាសម្បត្តិ ។

ចរិយាសម្បត្តិ ជាគុណសម្បត្តិចាំបាច់ចំពោះបុគ្គលិកសិក្សា ។ គ្រូត្រូវតែមានរឹកពារថ្លៃថ្នូរមិនប្រព្រឹត្តអបាយមុខ ដែលនាំអោយដល់នូវសេចក្តីវិនាស « ស្រី ស្រា ចាយវាយខ្ជះខ្ជាយ ល្បែង ភ្នាល់ សេពគប់ មនុស្សអាក្រក់ជាមិត្ត ខ្ជិលច្រអូស ដើរលេងយប់ ដើរមើលល្បែងរបាំទាល់តែញៀនជាប់ចិត្តឥតធ្វើការរបរអ្វី ទាំង ៨យ៉ាងនេះជាអបាយមុខ » ។

គ្រូត្រូវប្រើពាក្យសំដីនិយាយអោយបានត្រឹមត្រូវជាមួយសិស្ស ឪពុកម្តាយសិស្ស និងអ្នកដទៃ គឺចៀសវាងពាក្យ អា មីង មី ហ្អង ជាដើម ។ គ្រូត្រូវដាច់ខាតមិនស្រែកឡូឡា គំហកគំហែង និងមិននិយាយឡេះឡោះ កុហកភូតភរឡើយ ។ ម្យ៉ាងទៀតគ្រូត្រូវមានការអត់ធ្មត់ជានិច្ច មិនឆេវឆាវទៅតាមកំហឹង មិនវាយវាត់ដែលនាំអោយអាប់អោនកិត្តិយសគ្រូ ។ គ្រូត្រូវស្រឡាញ់រាប់អានសិស្សមិនរើសមុខ ។ នៅពេលបង្រៀនគ្រូកុំប្រកែងប្រជាង ខះគុផ្លូងផាង ស្រែកគំហកគំហែង កំញើញ សំលុតសិស្សឡើយ ។ ប៉ុន្តែគ្រូមិនត្រូវបណ្តោយអោយសិស្សធ្វើអ្វីបានតាមអំពើចិត្តទេ ។ សាលារៀនត្រូវតែមានវិន័យ ។ គ្រូរលុងមិនមែនជាលក្ខណៈគ្រូទេ ។ អ្នកអប់រំប៉ិនប្រសប់ចេះដឹកនាំសិស្សអោយមានរបៀបរៀបរយចេះប្រើអាកប្បកិរិយាគួរអោយសិស្សគោរព ។ ម្យ៉ាងទៀតលោកគ្រូ អ្នកគ្រូ ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋរស់នៅក្នុងភូមិ ឃុំជុំវិញសាលារៀន និងជាមួយព្រះសង្ឃ ដើម្បីជាគុណប្រយោជន៍ចំពោះសាលារៀន និងការសិក្សា ។ គ្រូត្រូវចៀសវាងទំនាស់ផ្សេងៗកើតឡើងដោយសារលោកគ្រូ អ្នកគ្រូ ។ បរិយាកាសដ៏ល្អរវាងអ្នកជិតខាងនាំមកនូវការយោគយល់គ្នា ។ តាមរយៈនេះគ្រូអាចបំផុសគំនិតរៀបចំលំនៅឋានតាមក្បួនអនាម័យ ស្ថាបនាភូមិឋានអោយមានសោភណភាព និងជួយដោះស្រាយបញ្ហាសង្គមនៅជុំវិញខ្លួន ។

នៅពេលក្រោយម៉ោងបង្រៀនលោកគ្រូ អ្នកគ្រូ ត្រូវតែឆ្លៀតធ្វើការងារជាមួយគ្រួសារដើម្បីបន្ថែមចំនួលថវិកាក្នុងគ្រាក្រលំបាកជីវភាពសព្វថ្ងៃ ។ គ្រូក៏ត្រូវឆ្លៀតផងដែរនូវអំនានទស្សនាវដ្ដី និងសៀវភៅផ្សេងៗ ដើម្បីបង្កើនចំនេះដឹងជាប្រចាំទាំងចំនេះដឹងទូទៅ និងគរុកោសល្យ ។

ដើម្បីរក្សាកិត្តិយសជាគ្រូ ជាអ្នកអប់រំ ខ្ញុំសូមលោកគ្រូ អ្នកគ្រូចៀសវាងទង្វើណាដែលមិនគប្បី ។ ពាក្យស្លោកមួយឃ្លាចែងថា « ក្រក៏ក្រចុះ អោយតែមាន » ជាពាក្យត្រឹមត្រូវគួរទុកជាដំបូន្មាន ។ ខ្ញុំសង្ឃឹមថា លោកគ្រូ អ្នកគ្រូមុខជាត្រិះរិះពិចារណាលើសំនេះខ្ញុំនេះដើម្បីរិះរកមធ្យោបាយលើកតំកើងតំលៃគ្រូ នាបច្ចុប្បន្ននេះ និងទៅអនាគត ។

**យ៉ង់ ធី**

# គ្រូល្អ សិស្សល្អ

# បង្រៀន គឺ អោយសិស្សមានចំនេះជាសារវន្ត

ដោយ **ឈិច សុត**

កម្មវិធីនៅបឋមសិក្សាធំទូលាយណាស់ ។ ពេលវេលារៀនស្ទួត្រខ្លី ។ ដូចនេះ គ្រូបង្រៀនមិនអាចបញ្ចប់កម្មវិធីសិក្សាដោយប្រសិទ្ធភាពបានទេ ។ កម្មវិធីសិក្សាផ្ទុកដោយសញ្ញាណដ៏ពោរពាសនៃការបង្រៀន រៀនអាន មេសូត្ររត់មាត់តែងសេចក្តី អក្សរផ្ចង់សរសេរតាមអាន វេយ្យាករណ៍ រៀនពាក្យ គណិតវិទ្យា សុភាវធមិ ពលរដ្ឋវិទ្យា វិទ្យាសាស្ត្រអនុវត្ត ប្រវត្តិវិទ្យា ភូមិវិទ្យា គំនូរ ការហត្ថកម្ម ចំរៀងសិល្បៈ កាយសិក្សា ។ល ។ គ្រូមិនអាចបង្រៀនសំនុំ សញ្ញាណទាំងនេះបានអស់ទេ ព្រោះគ្មានពេលគ្រប់គ្រាន់ ។

គេបានបង្គាប់ជាដាច់ខាតថា ៖

- « ឧត្តមគតិសាលាបឋមសិក្សាមិនមែន បង្រៀនច្រើនទេ ប៉ុន្តែបង្រៀនល្អ កុមារចេញពីសាលារៀន ចេះតិចប៉ុន្តែល្អ » ។
- « រៀនតិចប៉ុន្តែចងចាំបានល្អ អនុស្សាវរីយ៍ តិច ប៉ុន្តែអនុស្សាវរីយ៍ពេញលេញ និងតាមលំដាប់ » ។
- « ដើម្បីបង្រៀនអោយបានល្អ ដល់កុមារ នូវអ្វីដែលកុមារ ត្រូវតែដឹងដោយខានមិនបាន គ្រូត្រូវចេះជ្រើសរើស និងដាក់កំរិតទៅតាមអាយុ បញ្ញា នូវពុទ្ធិដែលត្រូវផ្ដល់ដល់កុមារ » ។
- « ការអប់រំខាងបញ្ញា ត្រូវមានចំនួនពុទ្ធិកំនត់មួយ ។ ពុទ្ធិទាំងនេះត្រូវជ្រើសរើសយ៉ាងណា ដើម្បីធានាដល់ចំនេះធ្វើដែលកុមារត្រូវយកទៅប្រើប្រាស់ក្នុងជីវិត » ។

ពាក្យថា « ជ្រើសរើស » តំរូវអោយគ្រូធ្វើ ជំរើសតាមវិធីសាស្ត្រ នូវសញ្ញាណទាំងឡាយដែលមានប្រយោជន៍ពិតប្រាកដដល់សិស្ស ។ ប្រការនេះមានន័យថា « បង្រៀន គឺជ្រើសរើស » ។

ចូរយើងសង្កេតមើល គ្រូបង្រៀនដែលបង្រៀនគ្មានការជ្រើសរើស ។ គាត់គោរពដោយយកចិត្តទុកដាក់ក្នុងការអនុវត្តកម្មវិធីសិក្សា ។ គាត់មិនអាចសំរេចជោគជ័យបានទេ ពីព្រោះគាត់មិនអាចបង្រៀនគ្រប់សញ្ញាណ ក៏ដូចជាមិនអាចអោយសិស្សទាំងអស់ ចាប់យកបាន នូវសញ្ញាណទាំងនេះបាន ។

ផ្ទុយទៅវិញ គ្រូបង្រៀនដែលចេះជ្រើសរើស និងចេះសំរបសំរួល បានល្អនូវកម្មវិធីសិក្សារបស់ថ្នាក់គាត់ គាត់ពិនិត្យកម្មវិធីសិក្សា មួយចំនុចម្តងៗ គាត់ដកចេញពីអ្វីដែលស្មុគ្រស្មាញ និងទុកតែអ្វីដែលសំខាន់ ។ គាត់ចេះប្រើបានសមរម្យ នូវសេរីភាព ដែលគេបានផ្តល់ជូនគាត់ក្នុងការយក និងដកចេញបញ្ញាណាមួយ ។ ការបង្រៀនរបស់គាត់ បានច្បាស់លាស់ជាក់លាក់ និងមានប្រសិទ្ធភាព ។ គឺជាករណីនៃ : « បង្រៀនតិច ប៉ុន្តែល្អ » ។

ហេតុផលបញ្ជាក់ពីរូបមន្ត « បង្រៀនគឺជ្រើសរើស »

កម្មវិធីសិក្សាធ្វើសំរាប់ទូទាំងប្រទេស ។ យើងមិនអាចអនុវត្ត កម្មវិធីសិក្សានេះអោយបាន ឯកភាពទូទាំងប្រទេសបានទេ ទីក្រុង ស្រុកស្រែ ស្រុក ចំការ តំបន់កោះស្ងួ តំបន់មាត់សមុទ្ទ . . . ។

« កម្មវិធីសិក្សា ធ្វើដើម្បីសិស្ស មិនមែនសិស្ស ដើម្បីកម្មវិធីសិក្សាទេ » ។

- កំរិតបញ្ញារបស់សិស្ស និងកំរិតការសិក្សារបស់សិស្ស : គេមិនអាចបង្រៀនពុទ្ធិ ដូចគ្នានូវមុខវិជ្ជាណាមួយសំរាប់សិស្សថ្នាក់ទី ៣ និងសំរាប់សិស្សថ្នាក់ទី ៥នោះបានទេ ។

- ធម្មជាតិរបស់សាលារៀន និងតំរូវការរបស់មជ្ឈដ្ឋាន តំរូវទៅលើការជ្រើសរើសនេះ សាលារៀន ស្រុកក្រុង ប្លែកពីសាលារៀន ស្រុកស្រែ រឺស្រុកចំការ ។

- ជ្រើសរើស គឺជ្រើសរើសតាមកំរិតថ្នាក់ ។ យើងមានការសាឡើងវិញ ក៏ពិតមែន ប៉ុន្តែត្រូវយកចិត្តទុកដាក់លើកំរិតរបស់ថ្នាក់នីមួយៗ : ថ្នាក់ទី ១ ទី ២ និង ទី ៣ គឺថ្នាក់បឋមសិក្សាជាន់ដំបូង និងថ្នាក់ទី ៤ ទី ៥ និង ទី ៦ ជាថ្នាក់បឋមសិក្សាបំពេញវិជ្ជា ។

ចំពោះស្ថានភាពខាងលើនេះ សាលារៀនបឋមសិក្សា ត្រូវតែអនុវត្តជានិច្ចកាលនូវការជ្រើសរើស តាមវិធីសាស្ត្រ ដើម្បីសំរេចការបង្រៀនមួយដែលមានតំលៃ និងមានប្រសិទ្ធភាព ។ បើមិនដូចនោះទេ សាលារៀនបឋមសិក្សារបស់យើងពិតជាមិនបានបំពេញ បេសកកម្មជាមូលដ្ឋានរបស់ខ្លួនគឺ « បង្រៀនតិច និង ល្អ » នោះបានទេ ។

អ្នកនិពន្ធបារាំង ដ៏ល្បីល្បាញម្នាក់បានមានប្រសាសន៍ថា : « អ្នកណាមិនចេះជ្រើសរើស អ្នកនោះមិនចេះបង្រៀន » ។

# វេទិកាសេរី

គណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ បើកវេទិកានេះ ក្នុងគោលបំណងអោយគ្រប់សមាជិកទាំងអស់ចេះរៀនគិត រៀនពិចារណា រៀនសរសេរបញ្ចេញមតិយោបល់ទាក់ទងនឹងបញ្ហាសង្គម វប្បធម៌ ដើម្បីជួយដោះស្រាយបញ្ហាជាតិ ។

ស្នាដៃ រឺ បទពិសោធន៍ល្អៗ ដែលគណៈកម្មាធិការកណ្តាលយល់ថា មានប្រយោជន៍គួរផ្សាយទៅគ្រប់សាលារៀនទូទាំងប្រទេស នឹងត្រូវបានទទួលរង្វាន់ពីសមាគម ។

យើងខ្ញុំសូមសង្ឃឹមញញឹមទុកជាមុនថា លោកគ្រូ - អ្នកគ្រូ ប្រាកដជាមានសន្តានចិត្តសប្បុរសផ្តល់អត្ថបទមកគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ ជាពុំខាន ។

# សំនួរស្រង់មតិយោបល់

គណៈកម្មាធិការកណ្តាលសូមបុគ្គលិកសិក្សាទាំងអស់ឆ្លើយជាឯកជន រឺ ជាក្រុម នូវសំនួរដូចខាងក្រោម ។ យើងខ្ញុំរីករាយនឹងទទួលមតិយោបល់លើខ្លឹមសារអត្ថបទចុះក្នុងទស្សនាវដ្តីគ្រូបង្រៀនទាំងពីរលេខកន្លងមកនេះ ដើម្បីទុកជាឧបករណ៍សំរាប់កែលំអខ្លឹមសារអត្ថបទដែលត្រូវចេញជាបន្តបន្ទាប់ ។

**សំនួរ :**

តើលោកគ្រូ អ្នកគ្រូ យល់ឃើញយ៉ាងណាចំពោះអត្ថបទទាំងឡាយដែលបានចុះក្នុងទស្សនាវដ្តី ៖

១- ខ្លឹមសារ ។ តើមានសារៈសំខាន់ចំពោះគ្រូយើងដែល រឺទេ ?

២- ទំរង់សំនេរ ។ ពិបាកយល់ ល្បះវែងពេក ? រឺសំញាំពេកក្តាប់ខ្លឹមសារមិនបាន ?

សូមលោកគ្រូ អ្នកគ្រូ មេត្តាផ្តល់យោបល់ដោយឥតលាក់លៀម និងធ្វើសំនូមពរមកយើងខ្ញុំនៅចុងបញ្ចប់សំនេរ ។

សូមអរគុណទុកជាមុន

គណៈកម្មាធិការកណ្តាល ស.ប.ស.ខ



ឧត្តរ (ជើង)
ពាយ័ព្យ
ឦសាន
បស្ចិម (លិច)
បូពិ (កើត)
និរតី
អគ្នេយ៍
ទក្សិណ (ត្បូង)